ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception): 08 / 04 / 2012
ម៉ោង (Time/Heure): 15:10
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de première instance

សំណុំរឿងលេខ: ០០២/១៩ កញ្ញា ២០០៧/អវតក/អជសដ
**Case File/Dossier No. 002/19-09-2007-ECCC/TC**

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម **និល ណុន ប្រធាន** |
| | ចៅក្រម **Silvia CARTWRIGHT** |
| | ចៅក្រម **យ៉ា សុខន** |
| | ចៅក្រម **Jean-Marc LAVERGNE** |
| | ចៅក្រម **យូរ ឧត្តរា** |
| កាលបរិច្ឆេទ: | ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២ |
| ភាសាដើម: | ខ្មែរ/អង់គ្លេស/បារាំង |
| ចំណាត់ថ្នាក់ឯកសារ: | **សាធារណៈ** សាធារណៈ / Public |

**សេចក្តីសម្រេចលើការជំទាស់ទៅនឹងឯកសារដែលបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា និងចំពោះឯកសារដែលបានដកស្រង់ នៅក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលពាក់ព័ន្ធនឹងសវនាការពីរដំណាក់កាល ដំបូង នៃសំណុំរឿង ០០២/០១**

| | |
|---|---|
| **<u>សហព្រះរាជអាជ្ញា</u>** | **<u>ជនជាប់ចោទ</u>** |
| ជា លាង | នួន ជា |
| Andrew CAYLEY | អៀង សារី |
| | ខៀវ សំផន |
| **<u>សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី</u>** | **<u>មេធាវីជនជាប់ចោទ</u>** |
| ពេជ អង្គ | សុន អរុណ |

Elisabeth SIMONNEAU FORT

Michiel PESTMAN
Victor KOPPE
Jasper PAUW
Andrew IANUZZI

**អាង ឧត្តម**

Michael G. KARNAVAS

**គង់ សំអុន**

Arthur VERCKEN
Jacques VERGÈS

00798276



# ១. សេចក្តីផ្តើម

១. អង្គជំនុំជម្រះសាលាដំបូងបានទទួលសំណើផ្ទាល់មាត់ របស់សហព្រះរាជអាជ្ញាសុំដាក់ឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A5[១] របស់ខ្លួននៅចំពោះមុខអង្គជំនុំជម្រះ។ អង្គជំនុំជម្រះសាលាដំបូងក៏បានទទួលផងដែរនូវការជំទាស់ទៅនឹងឯកសារមួយចំនួន ក្នុងចំណោមឯកសារទាំងនេះ រួមទាំងឯកសារទាំងឡាយដែលបានដកស្រង់នៅក្នុងជើងទំព័រនៃកថាខណ្ឌនានារបស់ដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងៗក្នុងសំណុំរឿង ០០២/០១ ដែលទាក់ទិននឹង ១) ប្រវត្តិបក្សកុម្មុយនីស្តកម្ពុជា និង ២) រចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនងការងារ និងធាតុផ្សំខ្លះៗនៃតួនាទីរបស់ជនជាប់ចោទ[២]។ សេចក្តីសម្រេចនេះពិចារណាទៅលើការជំទាស់ទាំងអស់នេះ និងសម្រេចថាតើឯកសារទាំងអម្បាលម៉ានខាងលើស្របទៅនឹងលក្ខណៈវិនិច្ឆ័យនៃការដាក់ឯកសារចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុងឬទេ ដោយរួមទាំងលក្ខណៈវិនិច្ឆ័យទាំងអស់ដែលមានចែងក្នុងវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងផង[៣]ដែរ។

---

[១] ប្រតិចារិក,ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៦៨; *សូមមើល* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទិននឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្តី, ឯកសារលេខ E109/4, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១; ឧបសម្ព័ន្ធ ១៖ ចម្លើយរបស់ជនជាប់ចោទ, ឯកសារលេខ E109/4.1; ឧបសម្ព័ន្ធ ២៖ ការបោះពុម្ពផ្សាយ និងសារាចរណែនាំរបស់ ប.ក.ក, ឯកសារលេខ E109/4.2; ឧបសម្ព័ន្ធ ៣៖ កំណត់ហេតុប្រជុំរបស់ ប.ក.ក, ឯកសារលេខ E109/4.3; ឧបសម្ព័ន្ធ ៤៖ លិខិតទំនាក់ទំនងកម្ពុជាប្រជាធិបតេយ្យ, ឯកសារលេខ E109/4. 4; ឧបសម្ព័ន្ធ ៥៖ សេចក្តីថ្លែងការណ៍សារព័ត៌មាន និងសាធារណៈកម្ពុជាប្រជាធិបតេយ្យ, ឯកសារលេខ E109/4.5។

[២] ប្រតិចារិក, ថ្ងៃទី ១៦-១៩ ខែ មករា ឆ្នាំ ២០១២ ("សវនាការលើឯកសារលើកទី១"); ប្រតិចារិក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ("សវនាការលើឯកសារលើកទី២")។

[៣] សម្រាប់សេចក្តីសម្រេចដែលពាក់ព័ន្ធ *សូមមើល* សេចក្តីសម្រេចលើសំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ ដោយអនុលោមតាមវិធាន ៣៥ នៃវិធានផ្ទៃក្នុង ពាក់ព័ន្ធនឹងភាពពុំត្រឹមត្រូវនៅក្នុងកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងជាសំឡេងនៃការស្តាប់ចម្លើយសាក្សីរបស់ ក.ច.ស.ច, ឯកសារលេខ E142/3, ចុះថ្ងៃទី ១៣ ខែ មីនា ឆ្នាំ ២០១២ (សេចក្តីសម្រេចលើកំណត់ហេតុជាសំឡេង"); ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារនានា (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១២), ឯកសារលេខ E159, ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២, ទំព័រ ២ (ដែលបានបង្ហាញថា អង្គជំនុំជម្រះមិនទាន់បានសម្រេចលើការជំទាស់ភាគច្រើនរបស់បុគ្គលទេ នៅពេលដែលការជំទាស់ទាំងនេះតំណាងជាសំខាន់ដល់ប្រភេទទូលាយនៃការជំទាស់ដែលធ្លាប់បានសម្រេចរួចមកហើយ ឬដែលពុំមានមូលដ្ឋានត្រឹមត្រូវ)

## ២. ប្រវត្តិនីតិវិធី

### ២.១. ឯកសារនានាដែលបានលើកនៅជើងទំព័រដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយ

២. នៅថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា លើកលែងតែមានដីកាបង្គាប់ផ្ទុយពីនេះ ឯកសារនានា ឬប្រភពផ្សេងទៀតដែលបានយោងនៅជើងទំព័រក្នុងផ្នែកខ្លះនៃដីកាដំណោះស្រាយ ដែលបានអានទៅក្នុងតុលាការមុនពេលចាប់ផ្តើមប្រធានបទសវនាការទីមួយ នឹងត្រូវសន្មតថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះអនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង[៤]។ នៅក្នុងសេចក្តីសម្រេចដោយផ្ទាល់មាត់របស់ខ្លួនកាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានបំភ្លឺថា សហចៅក្រមស៊ើបអង្កេតបានវាយតម្លៃពីភាពពាក់ព័ន្ធនៃឯកសារទាំងអស់ដែលបានដាក់នៅក្នុងសំណុំរឿង និងបានផ្តល់តម្លៃជាភស្តុតាងចំពោះភស្តុតាងនានាដែលបានលើកនៅក្នុងដីកាដំណោះស្រាយ (និងដោយសារដីកាដំណោះ

---

និងការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារ (ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២), ឯកសារលេខ E170, ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៦ (ដែលបានបង្ហាញថា តុលាការបានកំណត់ពេលសម្រាប់ទឡ្ហីករណ៍តទល់គ្នា ទាក់ទិននឹងប្រភេទឯកសារជាក់លាក់មួយចំនួន ដែលជាជម្រើសសម្រាប់ដាក់ការជំទាស់ជាលាយលក្ខណ៍អក្សរ)។ លើសពីនេះទៀត អង្គជំនុំជម្រះនឹងចេញសេចក្តីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញា សុំដាក់ចម្លើយសាក្សី និងឯកសារនានាពាក់ព័ន្ធនឹងសាក្សីទាំងនោះ នៅចំពោះមុខអង្គជំនុំជម្រះ ដែលលើកមកដេញដោល ដោយគ្មានវត្តមានរបស់សាក្សី (ចម្លើយរបស់សាក្សី) ក៏ដូចជាសំណើសុំដាក់ឯកសារថ្មីទៅក្នុងសំណុំរឿង (សេចក្តីសម្រេចលើឯកសារថ្មី)។

[៤] ការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E141, ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ២-៣; *សូមមើលផងដែរ* ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារនានា (ដែលនឹងប្រព្រឹត្តទៅចាប់ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ២០១២), ឯកសារលេខ E159, ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ ("ដីកាកំណត់កាលបរិច្ឆេទសវនាការលើឯកសារលើកទី១"), កថាខណ្ឌ ៥; និង សាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញក្រុមបន្ទាប់ ដែលអង្គជំនុំជម្រះនឹងស្តាប់សក្ខីកម្មក្នុងសំណុំរឿង ០០២/០១, ឯកសារលេខ E172, ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ (ដែលបានបង្ហាញថា កថាខណ្ឌនានានៅក្នុងដីកាដំណោះស្រាយពាក់ព័ន្ធនឹងផ្នែកសវនាការទាក់ទិននឹងរចនាសម្ព័ន្ធរដ្ឋបាល និងប្រព័ន្ធទំនាក់ទំនង និងធាតុផ្សំមួយចំនួននៃតួនាទីរបស់ជនជាប់ចោទដែលអាននៅក្នុងសាលសវនាការថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២)។ នៅថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១ និង ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ កថាខណ្ឌស្តីពីប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានៃដីកាដំណោះស្រាយត្រូវបានអាននៅក្នុងសាលសវនាការ និងដាក់នៅចំពោះមុខអង្គជំនុំជម្រះ (ប្រតិចារឹក, ថ្ងៃទី ០៥ ខែ ធ្នូ ឆ្នាំ ២០១១, ទំព័រ ១០-២៦ និង ប្រតិចារឹក, ថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២, ទំព័រ ៣-៣៣, ៣៥-៥៦)។

ស្រាយត្រូវបានប្ដឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ) ឯកសារនានាដែលបានលើកក្នុងផ្នែកខ្លះនៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធទៅនឹងដំណាក់កាលនីមួយៗនៃសវនាការក្នុងសំណុំរឿង ០០២/០១ ត្រូវបានសន្មតជាមុនពីភាពពាក់ព័ន្ធ និងភាពជឿជាក់បាន (រួមទាំងយថាភាពរបស់វាផង)។ ផ្អែកលើការវិភាគ *បឋម* ឯកសារដែលបានលើកក្នុងផ្នែកទាំងនោះដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២/០១ ត្រូវបានសន្មតថាមានភាពពាក់ព័ន្ធ និងអាចជឿជាក់បាន (រួមទាំងយថាភាពរបស់វា) (ពោលគឺស្របទៅនឹងលក្ខខណ្ឌតម្រូវនៃវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង) និងបានផ្ដល់ចំណាត់ថ្នាក់ E3 ដល់ឯកសារទាំងនោះ[៥]។

៣. ភាគីបានទទួលព័ត៌មានថា ប្រសិនបើភាគីមានបំណងជំទាស់ទៅនឹងការសន្មតជាមុនពីភាពពាក់ព័ន្ធ និងភាពជឿជាក់បានពាក់ព័ន្ធនឹងឯកសារជាក់លាក់នៅក្នុងប្រភេទឯកសារខាងលើ ពួកគាត់អាចទទួលបានឱកាសក្នុងការសាកសួរដេញដោលបាន។ ក្នុងពេលសវនាការពីថ្ងៃទី ១៦ ដល់ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២ ("សវនាការលើឯកសារលើកទី១") ភាគីមានឱកាសក្នុងការជំទាស់ទៅនឹងការសន្មតជាមុននេះ ទាក់ទិននឹងឯកសារដែលបានដកស្រង់នៅជើងទំព័រត្រង់ផ្នែកប្រវត្តិបក្សកុម្មុយនីស្តកម្ពុជានៃដីកាដំណោះស្រាយ[៦]។ នៅថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ ("សវនាការលើឯកសារលើកទី២") ភាគីក៏មានឱកាសស្រដៀងគ្នាដែរ ក្នុងការជំទាស់ទាក់ទិននឹងជើងទំព័រនៃកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងប្រព័ន្ធទំនាក់ទំនង និងរចនាសម្ព័ន្ធរដ្ឋបាល និងធាតុផ្សំមួយចំនួននៃតួនាទីរបស់ជនជាប់ចោទ[៧]។

---

[៥] ប្រតិចារិក, ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៨៥-៨៨។ *សូមមើលផងដែរ* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158 ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ("សេចក្ដីសង្ខេបនៃសេចក្ដីសម្រេចផ្ទាល់មាត់") កថាខណ្ឌ ៣ (ដោយកត់សម្គាល់ថា ចំណុចនេះអនុវត្តតែចំពោះឯកសារដែលបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ និងមិនចំពោះឯកសារដទៃទៀតដែលមានក្នុងសំណុំរឿងទេ)។

[៦] *សូមមើល* ការឆ្លើយតបទៅនឹងបញ្ហាដែលបានលើកឡើងដោយភាគីផ្សេងៗមុនពេលសវនាការ និងការកំណត់ពេលវេលានៃកិច្ចប្រជុំមិនផ្លូវការជាមួយនឹងមន្ត្រីជាន់ខ្ពស់ផ្នែកច្បាប់ នៅថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០១១, ឯកសារលេខ E141, ចុះថ្ងៃទី ១៧ ខែ វិច្ឆិកា ឆ្នាំ ២០១១, ទំព័រ ២ (ដែលបានបង្ហាញថា កថាខណ្ឌ ១៨-៣២, ៨៦២-៨៦៨, ៩៩៤-1000, ១០៩១, ១១២៦-១១៣០, ១៥៧៧-១៥៨៨ និង ១៥៩៨-១៦០០ នៃដីកាដំណោះស្រាយពាក់ព័ន្ធនឹងសវនាការនេះ)។

[៧] ការកំណត់កាលបរិច្ឆេទនៃសវនាការផ្ទាល់មាត់លើឯកសារ (ថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២), ឯកសារលេខ E170, ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៥ (ដែលបានបង្ហាញថា កថាខណ្ឌ ៣៣-១១២, ៨៦៦-៨៧២, ១០០១-១០១៥, ១១៣១-១១៤៤ និង ១១៤៧-១១៥០ ពាក់ព័ន្ធនឹងសវនាការនេះ)។

## ២.២ ឯកសារនានានៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា

៤. នៅថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានដាក់ឧបសម្ព័ន្ធចំនួន ២១ (A1-A21) នៃឯកសារដែលខ្លួនមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងអំឡុងពេលសវនាការដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២/០១[៨]។ ឧបសម្ព័ន្ធចំនួន ១០ ដំបូង (A1-A10) រួមមានឯកសារដែលបន្សល់ទុកពីសម័យកម្ពុជាប្រជាធិបតេយ្យ[៩]។ ឧបសម្ព័ន្ធ A11-A21 រួមមានឯកសារប្រភេទផ្សេងៗទៀតដែលសហព្រះរាជអាជ្ញាមានបំណងចង់ដាក់នៅចំពោះមុខអង្គជំនុំជម្រះ[១០]។

៥. ដោយបានបង្គាប់ឲ្យភាគីដាក់ឯកសារត្រឹមខែ មេសា និង ខែ មិថុនា ឆ្នាំ ២០១១ រួចមកហើយនោះ នៅថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១ អង្គជំនុំជម្រះសាលាដំបូងបានបង្គាប់ឲ្យភាគីបង្ហាញពីការជំទាស់ចំពោះឯកសារនានាដែលបានស្នើឡើងដោយភាគីដទៃទៀត ហើយការជំទាស់

---

[៨] ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសំណើរបស់អង្គជំនុំជម្រះសាលាដំបូងស្នើសុំឯកសារដែលទាក់ទងនឹងដំណាក់កាលដំបូងនៃការជំនុំជម្រះលើអង្គសេចក្ដី, ឯកសារលេខ E109/4, ចុះថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ចម្លើយតបនេះកំណត់អត្តសញ្ញាណឯកសារនានា ដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងពីឯកសារទាំងអស់ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងបញ្ជីឯកសារដើមរបស់សហព្រះរាជអាជ្ញា (*សូមមើល* បញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការ ស្របតាមវិធាន ៨០(៣), ឯកសារលេខ E9/31, ចុះថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១)។ ឧបសម្ព័ន្ធ ២១ រួមមានបញ្ជីឯកសារដែលមិនមានក្នុងសំណុំរឿង និងដែលមិនត្រូវបានបញ្ចូលក្នុងបញ្ជីរបស់សហព្រះរាជអាជ្ញាថ្ងៃទី ២២ ខែ កក្កដា ឆ្នាំ ២០១១។ ឧបសម្ព័ន្ធ ២១ នឹងត្រូវបានឆ្លើយតបនៅក្នុងសេចក្ដីសម្រេចលើឯកសារថ្មីៗ។

[៩] ឧបសម្ព័ន្ធ ១៖ ចម្លើយរបស់ជនជាប់ចោទ; ឧបសម្ព័ន្ធ ២៖ ការបោះពុម្ពផ្សាយ និងសារាចរណែនាំរបស់ ប.ក.ក; ឧបសម្ព័ន្ធ ៣៖ កំណត់ប្រជុំរបស់ ប.ក.ក; ឧបសម្ព័ន្ធ ៤៖ លិខិតទំនាក់ទំនងកម្ពុជាប្រជាធិបតេយ្យ; ឧបសម្ព័ន្ធ ៥៖ សេចក្ដីថ្លែងការណ៍សារព័ត៌មាន និងសាធារណៈកម្ពុជាប្រជាធិបតេយ្យ; ឧបសម្ព័ន្ធ ៦៖ ប្រវត្តិរូបកម្ពុជាប្រជាធិបតេយ្យ; ឧបសម្ព័ន្ធ ៧៖ កំណត់ហេតុពាណិជ្ជកម្មកម្ពុជាប្រជាធិបតេយ្យ; ឧបសម្ព័ន្ធ ៨៖ កំណត់ហេតុស្រុកត្រាំកក់; ឧបសម្ព័ន្ធ ៩៖ កំណត់ហេតុអ្នកទោសនៅមន្ទីរ ២១; ឧបសម្ព័ន្ធ ១០៖ ចម្លើយសារភាពនៅមន្ទីរ ស២១ (ឯកសារលេខ E109/4.1-4.10)។

[១០] ឧបសម្ព័ន្ធ ១១៖ ប្រតិចារឹកសវនាការសំណុំរឿង ០០១; ឧបសម្ព័ន្ធ ១២៖ ចម្លើយរបស់សាក្សី; ឧបសម្ព័ន្ធ ១៣៖ បណ្ដឹង; ឧបសម្ព័ន្ធ ១៤៖ របាយការណ៍កំណត់អត្តសញ្ញាណទីតាំងឧក្រិដ្ឋកម្ម; ឧបសម្ព័ន្ធ ១៥៖ ផែនទី និងរូបថត; ឧបសម្ព័ន្ធ ១៦៖ សំឡេង និងវីដេអូ; ឧបសម្ព័ន្ធ ១៧៖ លិខិតទំនាក់ទំនងអន្តរជាតិ; ឧបសម្ព័ន្ធ ១៨៖ របាយការណ៍សារព័ត៌មានអន្តរជាតិ; ឧបសម្ព័ន្ធ ១៩៖ អត្ថបទសិក្សាស្រាវជ្រាវ របាយការណ៍វិភាគ និងសៀវភៅ; ឧបសម្ព័ន្ធ ២០៖ របាយការណ៍ស្ដីពីការអនុវត្តដីកាបង្គាប់ឲ្យស៊ើបសួរជំនួស (*សូមមើល* ឧបសម្ព័ន្ធ ១-10; ឯកសារលេខ E109/4.1-4.10)។

បែបនេះត្រូវធ្វើឡើងមិនឲ្យហួសពីថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ទេ[១១]។ ក្រុមមេធាវីការពារក្តីបានដាក់ការជំទាស់របស់ខ្លួននៅថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២[១២]។

៦. នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានប្រកាសថា ខ្លួនមានបំណងដាក់ឯកសារដែលបន្សល់ទុកពីសម័យកម្ពុជាប្រជាធិបតេយ្យ ("DK") ដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A10[១៣] របស់សហព្រះរាជអាជ្ញា នៅចំពោះមុខអង្គជំនុំជម្រះ។ ដើម្បីផ្តល់ឱកាសដល់ភាគីក្នុងការបង្ហាញការជំទាស់របស់ខ្លួន ទៅនឹងឯកសារដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A5 ឱ្យកាន់តែមានភាពជាក់លាក់ និងដើម្បីឱ្យមូលដ្ឋាននៃការជំទាស់ទាំងនេះកាន់តែមានភាពពិស្តារទៀតនោះ អង្គជំនុំជម្រះសាលាដំបូងបានកំណត់កាលបរិច្ឆេទសម្រាប់សវនាការពីថ្ងៃទី ១៧ ដល់ទី ១៩ ខែ មករា ឆ្នាំ ២០១២[១៤]។ អង្គជំនុំជម្រះបានបង្ហាញថា ការជំទាស់ទៅនឹងឯកសារនានានៅក្នុងឧបសម្ព័ន្ធដទៃទៀតរបស់សហព្រះរាជអាជ្ញា រួមទាំងឯកសារនានាដែលបានស្នើសុំដោយភាគីដទៃទៀតនោះ នឹងត្រូវបើកសវនាការចាប់ពីថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២ តទៅ[១៥]។

---

[១១] បញ្ជីឈ្មោះសាក្សីសម្រាប់ការជំនុំជម្រះនៅដំណាក់កាលដំបូង, ពេលវេលាកំណត់សម្រាប់ការតវ៉ាអំពីការទទួលយកឯកសារ និងវត្ថុតាង និងចម្លើយតបទៅនឹងសំណើ E109/5, ឯកសារលេខ E131/1, ចុះថ្ងៃទី ២៥ ខែ តុលា ឆ្នាំ ២០១១, ទំព័រ ២។

[១២] ការជំទាស់ទៅនឹងភាពទទួលយកបាននៃបញ្ជីឯកសារដែលនៅសល់របស់ភាគីដទៃទៀត សម្រាប់ប្អូនវគ្គដំបូងនៃសវនាការលើកដំបូង, ឯកសារលេខ E131/1/1, ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២; ការជំទាស់សេចក្តីសង្កេត និងការជូនដំណឹងពាក់ព័ន្ធនឹងឯកសារនានាជាច្រើនដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ឯកសារលេខ E131/1/9, ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១២; ការជំទាស់របស់លោក អៀង សារី ចំពោះការទទួលយកឯកសារមួយចំនួនពីការិយាល័យសហព្រះរាជអាជ្ញាសម្រាប់សវនាការប្អូនវគ្គដំបូង, ឯកសារលេខ E131/1/10, ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២; ការជំទាស់ទៅនឹងឯកសារ និងសារណាបន្ថែមដោយអនុលោមតាមវិធាន ៩២, ឯកសារលេខ E131/1/12, ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២។

[១៣] ដីកាកំណត់កាលបរិច្ឆេទសវនាការលើឯកសារលើកទី១, កថាខណ្ឌ ៨។

[១៤] ដីកាកំណត់កាលបរិច្ឆេទសវនាការលើឯកសារលើកទី១, កថាខណ្ឌ ៨។

[១៥] សវនាការផ្ទាល់មាត់បន្ថែមទៀតលើឯកសារ (ដែលចាប់ផ្តើមថ្ងៃទី ១២ ខែ មីនា ឆ្នាំ ២០១២), ឯកសារលេខ E172/1, ចុះថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២ (ដែលត្រូវបានកែប្រែដោយអនុស្សរណៈដែលបានធ្វើបច្ចុប្បន្នភាពសម្រាប់សវនាការលើឯកសារនៅពេលក្រោយ (ចាប់ពីថ្ងៃទី ១២ ដល់ថ្ងៃទី ១៩ ខែ មីនា ឆ្នាំ ២០១២), ឯកសារលេខ E172/5, ចុះថ្ងៃទី ០២ ខែ មីនា ឆ្នាំ ២០១២)។ ការជំទាស់ទៅនឹងឯកសារនៅក្នុងឧបសម្ព័ន្ធ A11-A21 នឹងត្រូវដោះស្រាយក្នុងពេលវេលាសមស្រប។

## ២.៣. <u>បញ្ហាទូទៅដែលទាក់ទិននឹងប្រភពឯកសារនានា ដែលពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១</u>

៧. នៅថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ភាគីថា ប្រសិនបើមានឯកសារណាមួយលេចឡើងនូវបញ្ហាពិតប្រាកដទាក់ទិននឹងប្រភព ភាពជឿជាក់បាន ឬដំណើរការរក្សាទុកឯកសារនោះ អង្គជំនុំជម្រះសាលាដំបូងនឹងកោះហៅសាក្សីមកផ្តល់សក្ខីកម្មដើម្បីឆ្លើយតបទៅនឹងបញ្ហាទាំងនេះ[១៦]។ ក្នុងពេលសវនាការលើឯកសារលើកទី១ ក្រុមមេធាវីការពារក្តីបានស្នើថា នាយកមជ្ឈមណ្ឌលឯកសារកម្ពុជា (“DC-Cam”) លោក ឆាំង យុ គួរតែត្រូវបានកោះហៅមកផ្តល់សក្ខីកម្ម ដោយសារដំណើរការរក្សាទុកឯកសារ និងយថាភាពនៃឯកសារនានានៅក្នុងសំណុំរឿងមានប្រភពមកពី DC-Cam[១៧]។ ដោយសារ DC-Cam បានប្រគល់ជូនឯកសារមួយភាគធំ ក្នុងចំណោមឯកសារនៅក្នុងសំណុំរឿងពាក់ព័ន្ធនឹងសំណុំរឿង ០០២/០១ នោះ អង្គជំនុំជម្រះបានកោះហៅទាំងលោក វ៉ាន់ថាន់ ដារ៉ា (អនុប្រធាន DC-Cam) និង លោក ឆាំង យុ មកឆ្លើយតបជាទូទៅអំពីប្រភព និងយថាភាពនៃឯកសារដែលបានមកពីបណ្ណសារដ្ឋានរបស់ DC-Cam[១៨]។

## ៣. សារណា

៨. ទោះបីមានដីការបស់អង្គជំនុំជម្រះថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១១ ហើយសហព្រះរាជអាជ្ញាបានដាក់បញ្ជីឯកសារនៅខែ មេសា និង ខែ កក្កដា ឆ្នាំ ២០១១ ក៏ដោយ ក៏ក្រុមមេធាវីការពារក្តីបានលើកឡើងថា ពួកគាត់ពុំមានពេលវេលាគ្រប់គ្រាន់ក្នុងរៀបចំការជំទាស់ជាក់លាក់ទៅនឹង

---

[១៦] ដីកាកំណត់កាលបរិច្ឆេទសវនាការលើឯកសារលើកទី១, កថាខណ្ឌ ៨,ជើងទំព័រ ៤។ លោក ឆាំង យុ និង លោក វ៉ាន់ថាន់ ដារ៉ា មានឈ្មោះនៅក្នុងបញ្ជីសាក្សីរបស់សហព្រះរាជអាជ្ញា។

[១៧] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៨៣-៩០, ៩៤-៩៥, ១១៨-១២០, ១២៨; ប្រតិចារឹក, ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០១២, ទំព័រ ១៣-១៤, ៣៣-៣៩, ៥៩, ១០៨-១០៩។

[១៨] ប្រតិចារឹក, ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៣០-៣១។ បន្ទាប់មកសហព្រះរាជអាជ្ញាក៏បានដាក់បញ្ជីឯកសារទាំងអស់ដែលមានប្រភពពី DC-Cam (ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹងសំណើរបស់មេធាវីការពារក្តី នួន ជា ស្នើសុំបញ្ជីឯកសារដែលបានផ្តល់ជូនដោយមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) [...], ឯកសារលេខ E161, ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២; ឧបសម្ព័ន្ធ ក៖ ឯកសារដែលទទួលបានពីមជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam) ដែលបានបញ្ចូលក្នុងឧបសម្ព័ន្ធ ១-២០ នៃបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាសម្រាប់សវនាការដំណាក់កាលដំបូង ស្របតាមវិធាន ៨០ (៣), ឯកសារលេខ E161.1, ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២។

ឯកសារដែលបានស្នើដោយសហព្រះរាជអាជ្ញាទេ[១៩]។ ទោះជាយ៉ាងណាក្តី មេធាវីការពារក្តី អៀង សារី បានដាក់ការជំទាស់របស់ខ្លួន កាលពីថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ទៅនឹងឯកសារដែលកំណត់អត្តសញ្ញាណដោយសហព្រះរាជអាជ្ញានៅក្នុងឧបសម្ព័ន្ធ A1-A20 (លើកលែងតែឧបសម្ព័ន្ធ ៧)[២០]។ មេធាវីការពារក្តី នួន ជា បានគាំទ្ររាល់ការជំទាស់ទាំងអស់ដែលបានលើកឡើងដោយមេធាវីកាពារក្តី អៀង សារី និងបានលើកឡើងនូវការជំទាស់បន្ថែមទៀតទាក់ទិននឹងប្រភេទឯកសារជាក់លាក់[២១]។ មេធាវីការពារក្តី ខៀវ សំផន យោងទៅដល់ការជំទាស់របស់ខ្លួនប្រភេទនេះដែលបានលើកឡើងកន្លងមក[២២]។ ក្រុមមេធាវីការពារក្តីទាំងអស់បានទទួលឱកាសក្នុងការជំទាស់ផ្ទាល់មាត់ ទៅនឹងឯកសារ និងប្រភេទជាក់លាក់នៃឯកសារនានាក្នុងអំឡុងសវនាការលើកឯកសារលើកទី១ និងលើកទី២។

## ៣.១. <u>ឯកសារដែលបានដកស្រង់នៅជើងទំព័រពាក់ព័ន្ធនៃដីកាដំណោះស្រាយ</u>

៩. ទាក់ទិននឹងឯកសារនានាដែលបានដកស្រង់ នៅក្នុងផ្នែកដែលពាក់ព័ន្ធនៃដីកាដំណោះស្រាយ មេធាវីការពារក្តី អៀង សារី បានជំទាស់ទៅនឹង "ការទទួលយកឯកសារណាមួយដែលទំនងជាគ្មានយថាភាព ឬត្រូវបានបង្ហាញថាមានយថាភាព ដោយភាគីដែលព្យាយាមដាក់ឯកសារ

[១៩] សេចក្តីជំទាស់មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូងទាំងបួន, ឯកសារលេខ E131/1/11, ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ៤-៥; ការជំទាស់ ការកត់សម្គាល់ និងការជូនដំណឹងទាក់ទងនឹងឯកសារផ្សេងៗដែលត្រូវដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង, ឯកសារលេខ E131/1/9, ចុះថ្ងៃទី ១៤ ខែ វិច្ឆិកា ឆ្នាំ ២០១១, កថាខណ្ឌ ២០។

[២០] ការជំទាស់របស់លោក អៀង សារី ចំពោះការទទួលយកឯកសារមួយចំនួនពីការិយាល័យសហព្រះរាជអាជ្ញាសម្រាប់សវនាការបួនវគ្គដំបូង, ឯកសារលេខ E131/1/10, ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ (រួមមានការជំទាស់ចំពោះឯកសារទាំងអស់នៅក្នុងឧបសម្ព័ន្ធទាំងនេះ លើកលែងតែឯកសារនានានៅក្នុងឧបសម្ព័ន្ធ ៧ និង ២១ ដោយសំអាងថា ឧបសម្ព័ន្ធ ៧ រួមមានឯកសាររបស់ ក.ស.ព ពីសវនាការដំណាក់កាលដំបូង ដែលមេធាវីការពារក្តីបានជំទាស់រួចហើយ។ ឧបសម្ព័ន្ធ ២១ គឺជាបញ្ជីឯកសារថ្មីដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A20 ផ្សេងទៀត)។

[២១] ការជំទាស់ទៅនឹងឯកសារ និងសារណាបន្ថែម ដោយអនុលោមតាមវិធាន ៩២, ឯកសារលេខ E131/1/12, ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ២។

[២២] ការជំទាស់មិនទទួលយកបញ្ជីឯកសារសេសសល់ដែលដាក់ដោយភាគីផ្សេងទៀត សម្រាប់ការជំនុំជម្រះដំណាក់កាលដំបូងទាំងបួន, ឯកសារលេខ E131/1/11, ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២, កថាខណ្ឌ ៥។

នោះ”[២៣]។ គាត់ក៏បានជំទាស់ផងដែរចំពោះឯកសារមួយចំនួនក្នុងចំណោមឯកសារទាំងនេះ ដោយសំអាងថា៖

i. តម្លៃជាភស្តុតាងនៃភស្តុតាងដែលបានស្នើសុំត្រូវបានប៉ះពាល់ ដោយសារអានុភាពនៃភាពលម្អៀងរបស់វាទៅលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី (ទាក់ទិននឹងឯកសារចំនួន ៣៤)។

ii. ជនជាប់ចោទមានសិទ្ធិតទល់ទៅនឹងប្រភពព័ត៌មានដែលដាក់បន្ទុកមកលើខ្លួន (ឯកសារចំនួន ១០៣)។

iii. ឯកសារមួយចំនួនមិនអាចជឿជាក់បាន និងមិនសមស្របដើម្បីបង្ហាញពីអង្គហេតុដែលត្រូវសំអាងនោះទេ (ឯកសារចំនួន ៨២) និង

iv. កំណត់ហេតុជាលាយលក្ខណ៍អក្សរស្តីពីការស្តាប់ចម្លើយសាក្សីមិនអាចជឿជាក់បាន ដោយសារឯកសារទាំងនោះមិនបានតំណាងយ៉ាងត្រឹមត្រូវចំពោះការឆ្លើយតបរបស់សាក្សីទេ (ឯកសារចំនួន ១៧) និងមិនអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបានទេ ប្រសិនបើមិនបានបកប្រែជា ៣ ភាសានោះ (ឯកសារចំនួន ៤៩)[២៤]។

១០. មេធាវីការពារក្តីលោក អៀង សារី បានលើកឡើងបន្ថែមទៀតថា ឯកសារនានាដែលបានដកស្រង់នៅក្នុងដីកាដំណោះស្រាយដែលបានផ្តល់ឲ្យដោយលោក Steve Heder មិនគួរដាក់នៅចំពោះមុខអង្គជំនុំជម្រះទេ ដោយសំអាងថា លោក Heder បានបម្រើការងារឲ្យសហព្រះរាជ

---

[២៣] ការជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកឯកសារមួយចំនួនដែលមាននៅក្នុងជើងទំព័រក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយដែលត្រូវបានអាននៅក្នុងសាលសវនាការ, ឯកសារលេខ E156, ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ (“ការជំទាស់របស់ អៀង សារី ចំពោះជើងទំព័រ”) ទំព័រ ១។

[២៤] ការជំទាស់របស់ អៀង សារី ទៅនឹងឯកសារទាំងអស់ដែលបានកំណត់អត្តសញ្ញាណនីមួយៗដោយមេធាវីការពារក្តី អៀង សារី តាមពាក្យពេចន៍ខាងលើនៅក្នុងឧបសម្ព័ន្ធនៃការជំទាស់របស់ អៀង សារី ទៅនឹងការទទួលយកឯកសារជាក់លាក់មួយដែលមាននៅជើងទំព័រក្នុងកថាខណ្ឌនានានៃដីកាដំណោះស្រាយ ដែលបានអានក្នុងពេលសវនាការ, ឯកសារលេខ E156.2, ចុះថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០១១ (“ការជំទាស់របស់ អៀង សារី ទៅនឹងជើងទំព័រជាក់លាក់”); *សូមមើលផងដែរ* ចម្លើយតបរបស់លោក អៀង សារី ទៅនឹងសំណើរបស់សហព្រះរាជអាជ្ញា ដែលដាក់អមជាមួយនឹងបញ្ជីឈ្មោះអ្នកជំនាញ សាក្សី និងដើមបណ្តឹងរដ្ឋប្បវេណី អនុលោមតាមវិធាន ៨០, ឯកសារលេខ E9/4/1, ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ២០១១, កថាខណ្ឌ ២។

អាជ្ញាក្នុងការរៀបរៀងសេចក្ដីព្រាងដីកាសន្និដ្ឋានឱ្យស៊ើបសួរ ហើយបន្ទាប់មកគាត់បានបម្រើការងារឱ្យសហចៅក្រមស៊ើបអង្កេតក្នុងការ "បញ្ជាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរ ដោយការចូលរួមរបស់គាត់ទៅក្នុងការរៀបចំដីកាដំណោះស្រាយ"[២៥]។

១១. ខៀវ សំផន លើកឡើងអំពីភាពចាំបាច់ដែលតម្រូវឱ្យមានការបំភ្លឺទាក់ទិននឹងដំណើរការរក្សាទុកឯកសារ និងខ្លឹមសារយថាភាព និងភាពជឿជាក់បាន នៃឯកសារមួយចំនួន[២៦]។ អៀង សារី ក៏បានជំទាស់បន្ថែមទៀតទៅនឹងការទទួលយកសៀវភៅ និងអត្ថបទមួយចំនួន ដោយ អះអាងថា សៀវភៅ និងអត្ថបទទាំងនោះមិនគួរផ្ដល់តម្លៃជាភស្តុតាងទេ លុះត្រាតែមានការផ្ដល់ជូននូវព័ត៌មានបន្ថែមទៀតដូចជា ឈ្មោះអ្នកនិពន្ធ និងប្រភពរបស់វា[២៧]។ ខៀវ សំផន ក៏បានអះអាងផងដែរថា នៅពេលផ្នែកនានានៃសៀវភៅត្រូវបានដាក់សម្រាប់បុគ្គលដែលផ្ដល់ភស្តុតាងនៅពេលសវនាការ មានតែទំព័រនោះ ឬអត្ថបទដកស្រង់ទាំងនោះប៉ុណ្ណោះ ដែលអាចចាត់ទុកថាបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ[២៨]។ មេធាវីការពារក្ដី អៀង សារី លើកឡើងថា ពួកគេត្រូវមានឱកាសក្នុងការសាកសួរតទល់ចំពោះអ្នកសរសេរឯកសារទាំងអស់ ដែលពាក់ព័ន្ធនៅក្នុងសំណុំរឿង មុនពេលទទួលយកឯកសារទាំងនោះជាភស្តុតាង[២៩]។

១២. ទាំង អៀង សារី និង ខៀវ សំផន សុទ្ធតែអះអាងថា ចម្លើយរបស់ កាំង ហ្កេកអ៊ាវ *ហៅ ឌុច* ដែលបានផ្ដល់ក្នុងសំណុំរឿង ០០១ មិនអាចទទួលយកជាភស្តុតាងបានទេ លុះត្រាតែសាក្សីរូប

---

[២៥] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៣១-៣៣។

[២៦] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៣១, ៤៩ (ខៀវ សំផន) ដោយយោងទៅដល់ទូរលេខដែលបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ ដែលមេធាវីការពារក្ដី ខៀវ សំផន ពិចារណាថាមិនអាចជឿជាក់បាន ដោយសារពុំមានផ្ដល់ព័ត៌មានពីដំណើរការរក្សាទុកឯកសារ ដោយឡែកពាក់ព័ន្ធនឹងអ្នកសរសេរទូរលេខទាំងនេះតែម្ដង); *សូមមើល* ប្រតិចារឹក ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៣០-៣១ (អៀង សារី) (ដោយលើកជាទឡ្ហីករណ៍ថា ទូរលេខនៅផ្នែកពាណិជ្ជកម្ម គួរតែត្រូវបានផ្ដល់តម្លៃជាភស្តុតាងតិចតួច លុះត្រាតែកោះហៅសាក្សីដើម្បីបង្ហាញពីរបៀបសរសេរ និងបញ្ជូនទូរលេខ)។

[២៧] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៤៧ (អៀង សារី)។

[២៨] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ១២២-១២៣ (ខៀវ សំផន); *សូមមើលផងដែរ* សំណើធ្វើប្រតិកម្មតបនឹងការលំបាកជាច្រើនដែលបានចោទឡើងដោយសារសារអេឡិចត្រូនិករបស់លោកស្រី Lamb ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២" ("សំណើរបស់ ខៀវ សំផន ពាក់ព័ន្ធនឹងការរៀបចំសវនាការ"), ឯកសារលេខ E167, ចុះថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ១៧។

[២៩] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៣០-៣១។

នេះផ្តល់សក្ខីកម្មដោយមានសម្បថក្នុងសំណុំរឿង ០០២[៣០]។

១៣. សហព្រះរាជអាជ្ញាឆ្លើយតបថា ឯកសារចំនួន ៩៥ ដែលបានដកស្រង់នៅក្នុងដីកាដំណោះស្រាយ និងដែលត្រូវបានយកមកពិចារណាក្នុងអំឡុងពេលសវនាការលើឯកសារលើកទី២ នោះត្រូវបានសន្មតថាមានភាពពាក់ព័ន្ធ អាចជឿជាក់បាន និងមានយថាភាព។ អង្គជំនុំជម្រះសាលាដំបូងបានសន្និដ្ឋានរួចមកហើយថា របាយការណ៍ ព្រឹត្តិប័ត្រ ឬភាពយន្តឯកសារដែលបានទទួលពីប្រភពព័ត៌មាន ប្រសិនបើមានការពាក់ព័ន្ធ ត្រូវបានចាត់ទុកជាឯកសារដែលអាចដាក់នៅចំពោះមុខអង្គជំនុំជម្រះបាន។ សហព្រះរាជអាជ្ញាបានលើកឡើងថា លោក Heder បានបញ្ចប់ការងារពីការិយាល័យរបស់ពួកខ្លួន មុនពេលដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរត្រូវបានសរសេរនៅក្នុងត្រីមាសទី២ ឆ្នាំ ២០០៧ ទៅទៀត[៣១]។ ជាងនេះទៀត អៀង សារី មិនបានផ្តល់សំអាងហេតុណាមួយដើម្បីគាំទ្រដល់អំណះអំណាងដែលថា អន្តរាយដែលធ្វើឱ្យខូចប្រយោជន៍មានទម្ងន់ជាងតម្លៃជាភស្តុតាងនៃឯកសារជាក់លាក់មួយចំនួន ឬថាឯកសារមួយចំនួនមិនសមស្របនឹងយកមកបង្ហាញអង្គហេតុដែលត្រូវបង្ហាញនោះទេ។ សិទ្ធិក្នុងការកោះហៅអ្នកនិពន្ធនៃឯកសារនានាទេ មិនមែនជាសិទ្ធិដាច់ខាតនោះទេ ហើយសិទ្ធិរបស់ជនជាប់ចោទត្រូវបានការពារយ៉ាងពេញលេញដោយលទ្ធភាពរបស់មេធាវីការពារក្តីក្នុងការប្រៀបធៀបខ្សែអាត់សំឡេងនៃការស្តាប់ចម្លើយសាក្សី ជាមួយកំណត់ហេតុជាលាយលក្ខណ៍អក្សរ និងការលើកឡើងនូវភាពពុំស៊ីសង្វាក់គ្នា ប្រសិនបើមាន[៣២]។

១៤. ដើមបណ្តឹងរដ្ឋប្បវេណីយល់ស្របថា សហចៅក្រមស៊ើបអង្កេតបានទទួលយករួចហើយនូវយថាភាព និងភាពពាក់ព័ន្ធនៃឯកសារដែលបានលើកនៅក្នុងដីកាដំណោះស្រាយ[៣៣]។ ពួកគេលើកឡើងបន្ថែមទៀតថា មេធាវីការពារក្តីត្រូវបង្ហាញពីរបៀបដែលខ្លួនជំទាស់ទៅនឹងការ

---

[៣០] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៣៤, ៥៧, ៦៤; *សូមមើលផងដែរ* សារណារបស់លោក អៀង សារី ស្នើសុំមិនឲ្យទទួលយកនូវរាល់ចម្លើយទាំងអស់របស់ កាំង ហ្កេកអ៊ាវ ហៅ "ឌុច" ជាភស្តុតាង លុះត្រាតែ ឌុច បង្ហាញខ្លួនក្នុងតុលាការ ក្នុងនាមជាសាក្សី ព្រមទាំងស្នើសុំឲ្យ ក.ស.ព និងអង្គជំនុំជម្រះសាលាដំបូង បង្ហាញនូវចម្លើយមិនពិតនានារបស់ ឌុច ។

[៣១] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៨២។

[៣២] ប្រតិចារឹក, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៧, ១០ និង ២៥។

[៣៣] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៧៣-៧៤, ៧៨ និង ៨៥។

សន្និដ្ឋានពីភាពជឿជាក់បាន ដែលជាប់ជាមួយប្រភពទាំងនេះ មុននឹងដកការសន្និដ្ឋាននេះចេញ[៣៤]។

## ៣.២. ឯកសារនានានៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា

១៥. មេធាវីការពារក្ដីជំទាស់ការទទួលយកឯកសារនានានៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញាដោយសំអាងថា៖

i. តម្លៃជាភស្តុតាងនៃភស្តុតាងដែលបានស្នើសុំត្រូវបានប៉ះពាល់ ដោយសារអានុភាពនៃភាពលម្អៀងរបស់វាទៅលើភាពត្រឹមត្រូវនៃកិច្ចដំណើរការនីតិវិធី (ទាក់ទិននឹងឯកសារចំនួន ៣៨៩)។

ii. ប្រតិចារឹកនៃចម្លើយផ្ទាល់មាត់មិនអាចជឿជាក់បាន ប្រសិនបើពុំមានផ្ដល់នូវខ្សែអាត់សំឡេងដើមនៃចម្លើយទាំងនោះ (ឯកសារចំនួន ៣០៥)។

iii. ជនជាប់ចោទមានសិទ្ធិតទល់ទៅនឹងអ្នករៀបរៀងឯកសារ ឬចម្លើយដែលដាក់បន្ទុកមកលើខ្លួន (ឯកសារចំនួន ៣៦៥)។

iv. ឯកសារថ្មីៗត្រូវតែឆ្លើយតបទៅនឹងលក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង មុននឹងដាក់នៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារចំនួន ៣៦)។

v. ឯកសារមួយត្រូវចាត់ទុកថាមិនអាចជឿជាក់បាន ប្រសិនបើមិនមានឈ្មោះអ្នករៀបរៀង ឬប្រសិនបើពុំមានដំណើរការរក្សាទុកឯកសារ ដើម្បីសម្រេចពីប្រភពដើមរបស់វា (ឯកសារចំនួន ៥)។

vi. ឯកសារដែលបានបង្កើតឡើងនៅក្រោយយុត្តាធិការពេលវេលារបស់ អ.វ.ត.ក គឺពុំពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង ០០២/០១ ទេ (ឯកសារចំនួន ១១៩)។

vii. ឯកសារជាក់លាក់មួយចំនួនពុំមានទាំង ៣ ភាសា ផ្លូវការ របស់ អ.វ.ត.ក ហើយហេតុនេះឯកសារទាំងនោះមិនអាចទទួលយកបានទេ (ឯកសារចំនួន ៤៥)។

viii. ចម្លើយដែលបានផ្ដល់ដោយជនជាប់ចោទក្នុងអំឡុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក

---

[៣៤] ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៨២-៨៦។

មិនគួរដាក់នៅចំពោះមុខអង្គជំនុំជម្រះទេ លុះត្រាតែសហព្រះរាជអាជ្ញាអាចបង្ហាញឱ្យបានពេញលេញពីភាពពាក់ព័ន្ធនៃឯកសារទាំងនេះ (ឯកសារចំនួន ៦)។

ix. វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងតម្រូវថា សហព្រះរាជអាជ្ញាត្រូវបង្ហាញឱ្យបានពេញលេញនូវយថាភាព ភាពជឿជាក់បាន និងភាពពាក់ព័ន្ធនៃឯកសារទាំងអស់ (ឯកសារចំនួន ៣០៨)។

x. ឯកសារជាក់លាក់មួយចំនួនមិនពាក់ព័ន្ធនឹងប្រធានបទសម្រាប់សំណុំរឿង ០០២/០១ ទេ (ឯកសារចំនួន ១១៨)។ និង

xi. ចម្លើយសារភាពដែលផ្តល់នៅពេលធ្វើទារុណកម្មមិនអាចទទួលយកបានទេនៅក្នុងកិច្ចដំណើរការនីតិវិធីនៅ អ.វ.ត.ក លើកលែងតែប្រឆាំងនឹងជនជាប់ចោទណាម្នាក់ពីភស្តុតាងដែលបានមកពីការធ្វើទារុណកម្មនោះ (ឯកសារចំនួន ៦២)[៣៥]។

១៦. ក្នុងការឆ្លើយតបវិញ សហព្រះរាជអាជ្ញារំឭកថា នៅថ្ងៃទី ១៩ ខែ មេសា ឆ្នាំ ២០១១ ពួកគេបានជូនដំណឹងដល់ភាគីអំពីឯកសារនីមួយៗដែលចាត់ទុកថាពាក់ព័ន្ធ ដោយមានការពន្យល់ពិស្តារអំពីឯកសារទាំងនោះផង និងភាពពាក់ព័ន្ធនៃឯកសារទាំងនោះទៅនឹងផ្នែកភាគច្រើននៃដីកាបញ្ជូនរឿងទៅជំនុំជម្រះ[៣៦]។ នៅក្នុងសារណារបស់ខ្លួនចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ សហព្រះរាជអាជ្ញាបានកំណត់បន្ថែមទៀតនូវសញ្ញាណនានានៃភាពជឿជាក់បាន ចំពោះ

---

[៣៥] *សូមមើល* ការជំទាស់របស់លោក អៀង សារី ចំពោះការទទួលយកឯកសារមួយចំនួនពីការិយាល័យសហព្រះរាជអាជ្ញាសម្រាប់សវនាការបួនវគ្គដំបូង, ឧបសម្ព័ន្ធ A1-A5 ឯកសារលេខ E131/1/10.1-E131/1/10.5, ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ២០១២ ("ការជំទាស់របស់ អៀង សារី"); *សូមមើលផងដែរ* បញ្ជីឯកសារ និង វត្ថុតាងរបស់ អៀង សារី សម្រាប់ប្រធានបទជំនុំជម្រះបួនដំបូង, ឯកសារលេខ E109/6, ចុះថ្ងៃទី ០៨ ខែ សីហា ឆ្នាំ ២០១១។ មេធាវីការពារក្តី អៀង សារី បានលើកឡើងបន្ថែមទៀតថា នៅគ្រប់ករណីទាំងអស់ ឯកសារត្រូវតែដាក់ទៅឱ្យសាក្សីមុននឹងទទួលយកជាភស្តុតាង (ការជំទាស់របស់ អៀង សារី ទៅនឹងជើងទំព័រជាក់លាក់; *សូមមើលផងដែរ* ប្រតិចារឹក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, ទំព័រ ១០៣)។ អៀង សារី និង ខៀវ សំផន លើកឡើងថា ឯកសារនានាដែលមិនមានជាភាសាផ្លូវការរបស់ អ.វ.ត.ក ត្រូវតែបកប្រែ និងប្រធានបទដែលត្រូវជំទាស់បន្ថែមទៀត ប្រសិនបើចាំបាច់ (ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៤១, ទំព័រ ៥០-៥១)។ នួន ជា លើកឡើងថា ឯកសារជាច្រើននៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា ពុំពាក់ព័ន្ធទៅនឹងសវនាការដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២ ទេ (ប្រតិចារឹក, ថ្ងៃទី ១៦ ខែ មករា ឆ្នាំ ២០១២, ទំព័រ ២៧-២៩ និង ប្រតិចារឹក, ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៣៦)។

[៣៦] ប្រតិចារឹក, ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៥០។

ឯកសារចំនួន ៩៧៨ នៅក្នុងបណ្ដុំឯកសាររបស់ខ្លួននាពេលបន្ទាប់មក ដែលពាក់ព័ន្ធនឹងសវនាការដំណាក់កាលដំបូងក្នុងសំណុំរឿង ០០២/០១។ សហព្រះរាជអាជ្ញាលើកឡើងថា ឯកសារភាគច្រើនក្នុងចំណោមចំនួន ៩៧៨ នោះ ជាឯកសារផ្លូវការដែលត្រូវបានបង្កើតឡើងក្រោមការគ្រប់គ្រងរបស់អាជ្ញាធរនៃរបបកម្ពុជាប្រជាធិបតេយ្យ ដែលឯកសារទាំងនេះត្រូវបានបែងចែកជាច្រើនប្រភេទ និងសំដៅដល់ឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A20[៣៧]។ សហព្រះរាជអាជ្ញាក៏បានលើកឡើងបន្ថែមទៀតថា ឯកសារទាំងនេះបានទទួលពី DC-Cam ក្នុងពេលបើកកិច្ចស៊ើបសួរ ដែលវិធីសាស្ត្រក្នុងការប្រមូល ដំណើរការរក្សាទុក និងការផ្ដល់យថាភាពនៃឯកសារត្រូវបានពន្យល់យ៉ាងច្បាស់ពីលោក ឆាំង យុ នាយក DC-Cam រួចមកហើយ ហេតុនេះឯកសារទាំងអស់អាចជឿជាក់បាន[៣៨]។ ឯកសារភាគច្រើននៃសេចក្ដីថ្លែងការណ៍ជាសាធារណៈ ឬការសួរយកចម្លើយពីជនជាប់ចោទ ដែលមាននៅក្នុងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញាក៏ជាកំណត់ត្រាពីព្រឹត្តិការណ៍នានាពីសម័យនោះ ដែលបានកើតឡើងក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ហើយក៏មានសញ្ញាណនៃភាពជឿជាក់បាន និងយថាភាពរឹងមាំដែរ[៣៩]។ ហេតុនេះ ឯកសារទាំងអស់ដែលមាននៅក្នុងឧបសម្ព័ន្ធទាំងនេះ ស្របទៅតាមលក្ខខណ្ឌតម្រូវសម្រាប់ភាពទទួលយកបាននៃឯកសារដែលមានចែងក្នុងវិធាន ៨៧ (៣) នៃវិធានផ្ទៃក្នុង។

---

[៣៧] សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញា ស្របតាមវិធាន ៩២ ទាក់ទិននឹងសួចនាអំពីការជឿទុកចិត្តចំពោះឯកសារចំនួន ៩៧៨ ដែលជាប់ពាក់ព័ន្ធនឹងសាក្សី និងអ្នកជំនាញដែលអាចកោះហៅសម្រាប់សវនាការបីសប្ដាហ៍ដំបូង, ឯកសារលេខ E158, ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ២០១១ ("សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៩២"), កថាខណ្ឌ ២ (ដោយបានផ្ដល់ជាឧទាហរណ៍ពីលក្ខណៈខាងក្នុងនិងខាងក្រៅដែលអាចជឿជាក់បាន នៅពេលវាយតម្លៃពីប្រភពឯកសារ និងការវិភាគឯកសារទាំងនោះ។ លក្ខណៈខាងក្នុងដែលពាក់ព័ន្ធរួមមានលក្ខណៈសម្គាល់ឯកសារ ទម្រង់ ប្រភព/អ្នកសរសេរ, ការបរិច្ឆេទសរសេរ, ខ្លឹមសារ, គោលបំណង និងភាពស៊ីសង្វាក់គ្នាខាងក្នុង ដែលលក្ខណៈខាងក្រៅរួមមានយថាភាពអត្តសញ្ញាណ ភស្តុតាងបន្ថែម ការរកឃើញ និងការរក្សាទុកឯកសារ)។

[៣៨] សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៩២, កថាខណ្ឌ ៤-៥។

[៣៩] សេចក្ដីសន្និដ្ឋានរបស់សហព្រះរាជអាជ្ញាស្របតាមវិធាន ៩២, កថាខណ្ឌ ៧-២៦, ៣៧-៥០ (ដោយកត់សម្គាល់ថា ដោយឡែក ការបោះពុម្ពផ្សាយរបស់បក្សកុម្មុយនីស្តកម្ពុជា ("ប.ក.ក") បានប្រើសំនួរវោហារស័ព្ទដោយឡែកដែលស្របទៅនឹង ប.ក.ក រួមមានលក្ខណៈសម្គាល់ស៊ីសង្វាក់គ្នា និងមានសណ្ឋានស្រដៀងគ្នា។ ជាងនេះទៀត សាក្សីនានាបានបញ្ជាក់ពីយថាភាពនៃការបោះពុម្ពផ្សាយជាច្រើននៃទស្សនាវដ្ដីទង់បដិវត្តន៍ និង ឯកសារ ប.ក.ក ដទៃទៀត; *សូមមើលផងដែរ* ប្រតិចារឹក, ថ្ងៃទី ២១ ខែ ធ្នូ ឆ្នាំ ២០១១, ទំព័រ ៧៣-៧៤)។

## ៣.៣. ពាក្យសុំពាក់ព័ន្ធផ្សេងទៀតរបស់មេធាវីការពារក្តី

១៧. នួន ជា ក៏បានស្នើទៅអង្គជំនុំជម្រះសាលាដំបូងផងដែរ សុំឱ្យបង្គាប់ទៅសហព្រះរាជអាជ្ញាឱ្យទទួលយកព័ត៌មានបន្ថែមមួយចំនួនពី DC-Cam ដោយសំអាងថា ភាគីស្នើសុំឱ្យទទួលយកឯកសារមានកាតព្វកិច្ចផ្តល់ជូនអង្គជំនុំជម្រះនូវព័ត៌មានដែលពាក់ព័ន្ធដល់យថាភាព ប្រភព និងដំណើរការរក្សាទុកឯកសារ ប្រសិនបើមានព័ត៌មានទាំងនេះ[៤០]។ ដោយឡែក គាត់បានស្នើសុំឱ្យបង្ហាញព័ត៌មានដែលមាននៅក្នុងមូលដ្ឋានទិន្នន័យចំនួន ២ របស់ DC-Cam ដើម្បីបំភ្លឺពីប្រភព និងដំណើរការរក្សាទុកឯកសារដែលសហព្រះរាជអាជ្ញាបានពណ៌នា[៤១]។ នួន ជា លើកឡើងថា សិទ្ធិរបស់គាត់ក្នុងការទទួលបានសវនាការប្រកបដោយយុត្តិធម៌ តម្រូវឱ្យអង្គជំនុំជម្រះស្វែងរកការបំភ្លឺបន្ថែមទាំងនេះ ដោយសារព័ត៌មាននេះពាក់ព័ន្ធទៅនឹងទម្ងន់ជាភស្តុតាងដែលផ្តល់ឱ្យឯកសារទាំងនេះ[៤២]។

១៨. សហព្រះរាជអាជ្ញាលើកឡើងថា ការស្រាវជ្រាវហ្មត់ចត់មួយ ពាក់ព័ន្ធនឹងប្រភព និងដំណើររក្សាឯកសារនីមួយៗ ពុំមែនជាបុរេលក្ខខណ្ឌសម្រាប់ការទទួលយកឯកសារឡើយ។ ឯកសារចាំបាច់គ្រាន់តែបំពេញនូវបទដ្ឋាននៃ *សេចក្តីបញ្ជាក់បឋម* នៃភាពជាប់ពាក់ព័ន្ធ និងភាពអាចជឿជាក់បាន និងយថាភាពរបស់ឯកសារ ដែលមានតែប៉ុណ្ណោះ។ មជ្ឈមណ្ឌលឯកសារកម្ពុជាផ្តល់មូលដ្ឋានទិន្នន័យ ឬបណ្ណសារដ្ឋានដែលសាធារណជនអាចពិនិត្យមើលបាន ដែលតាមរយៈនេះ ភាគីត្រូវបានអនុញ្ញាតឱ្យធ្វើការស្រាវជ្រាវ និងប្រមូលឯកសារ។ លើសពីនេះទៅទៀតឯកសារ

---

[៤០] សារណាបន្ថែម ដែលទាក់ទងនឹងសំណុំសុំបំភ្លឺអំពីប្រភពនៃឯកសារ/ដំណើរការរក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (DC-Cam), ឯកសារលេខ E1/39.1/1, ថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ២០១២ (សារណារបស់ នួន ជា ពាក់ព័ន្ធនឹង DC-Cam), កថាខណ្ឌ ៨, ១៦។

[៤១] សារណារបស់ នួន ជា ពាក់ព័ន្ធនឹង DC-Cam, កថាខណ្ឌ ២-៥ និង ១៥។ មូលដ្ឋានទិន្នន័យទី១ ក្នុងចំណោមមូលដ្ឋានទិន្នន័យទាំងនេះដែលមានចំណងជើងថា "កំណត់សម្គាល់ពីប្រភពឯកសារ (៣១៧)" ត្រូវបានអះអាងថាបានកត់ត្រានូវព័ត៌មានស្តីពីប្រភព និងម្ចាស់ឯកសារពីមុន/បច្ចុប្បន្ន។ មូលដ្ឋានទិន្នន័យទី២ ដែលមានចំណងជើងថា "កំណត់សម្គាល់ទាក់ទិននឹងឯកសារដែលបានចាត់ថ្នាក់ (៣១៦)" រួមមានព័ត៌មានថាតើ DC-Cam មានឯកសារដើមនៃឯកសារនោះ ឬឯកសារថតចម្លង។

[៤២] សារណារបស់ នួន ជា ពាក់ព័ន្ធនឹង DC-Cam, កថាខណ្ឌ ៦ និង ១៤ (ដោយអះអាងថា ដោយសារគាត់មិនស្វែងរកការទទួលយកភស្តុតាងថ្មី តែគាត់បានស្នើសុំឱ្យបំភ្លឺចំពោះឯកសារដែលមានស្រាប់នោះ មេធាវីការពារក្តី នួន ជា ពុំចាំបាច់បំពេញតាមលក្ខខណ្ឌតម្រូវសម្រាប់ឯកសារថ្មីតាមវិធាន ៨៧(៤) ទេ។

ទាំងអស់នៃមជ្ឈមណ្ឌលឯកសារកម្ពុជា បានស្ថិតនៅក្នុងសំណុំរឿងយ៉ាងហោចណាស់ចំនួន ២ ទៅ៣ឆ្នាំ។ ហេតុដូច្នេះ មេធាវីការពារក្តីមានឱកាសច្រើនដើម្បីស្នើសុំការបញ្ជាក់បំភ្លឺទាំងអស់នេះឱ្យបានមុននេះ ហើយសំណើនាពេលបច្ចុប្បន្ន មានហានិភ័យក្នុងការអូសបន្លាយកិច្ចដំណើរការនីតិវិធីដោយពុំចាំបាច់[៤៣]។

១៩. កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ មេធាវីការពារជនជាប់ចោទ ខៀវ សំផន ក៏បានស្នើសុំឱ្យអង្គជំនុំជម្រះសាលាដំបូង បង្គាប់មជ្ឈមណ្ឌលឯកសារកម្ពុជា ឱ្យបញ្ជូនឯកសារដើមនៃឯកសារទាំងអស់ដែលត្រូវបានដាក់នៅក្នុងសំណុំរឿង មក អ.វ.ត.ក និងបញ្ជាក់បំភ្លឺអំពីដំណើររក្សាឯកសាររបស់ខ្លួន[៤៤]។ ជាចម្លើយតប សហព្រះរាជអាជ្ញាលើកឡើងថា ពុំមានលក្ខខណ្ឌតម្រូវគតិយុត្តណាមួយសម្រាប់ការដាក់បង្ហាញឯកសារដើមទាំងអស់ ពីមជ្ឈមណ្ឌលឯកសារកម្ពុជា នៅដំណាក់កាលនេះ នៃកិច្ចដំណើរការនីតិវិធីឡើយ ហើយឯកសារដើមត្រូវបានពិគ្រោះក្នុងអំឡុងដំណើរការនៃកិច្ចស៊ើបសួរតាមផ្លូវតុលាការ ហើយឯកសារថតចម្លងត្រូវបានដាក់ក្នុងសំណុំរឿង ហើយឧបសគ្គចម្បងខាងផ្នែកព័ស្តុភារ និងឧបសគ្គផ្សេងៗ នឹងកើតមាន ប្រសិនបើមានការតម្រូវឱ្យរក្សាទុករាល់ឯកសារដើមទាំងអស់ នៃមជ្ឈមណ្ឌលឯកសារកម្ពុជានៅ អ.វ.ត.ក សម្រាប់ថិរវេលានៃការជំនុំជម្រះនោះ[៤៥]។

## ៤. សំអាងហេតុ

### ៤.១. សេចក្តីផ្តើម

២០. កាលពីថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២ អង្គជំនុំជម្រះសាលាដំបូងបានធ្វើការបញ្ជាក់បំភ្លឺថា ភស្តុតាងទាំងអស់ ដែលបានយោងនៅក្នុងផ្នែកទាំងប៉ុន្មាននៃដីកាដំណោះស្រាយ ដែលពាក់ព័ន្ធនឹងចំណុចអង្គហេតុនីមួយៗដែលត្រូវធ្វើសវនាការក្នុងសំណុំរឿង ០០២/០១ ត្រូវបានសន្មតថា

[៤៣] ប្រតិចារិក., ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៨៥-៨៧; *សូមមើលផងដែរ* ចម្លើយតបរបស់សហព្រះរាជអាជ្ញាទៅនឹងសារណាបន្ថែមរបស់ នួន ជា ទាក់ទងនឹងសំណើសុំការបញ្ជាក់អំពីប្រភពដើម/ខ្សែសង្វាក់នៃការគ្រប់គ្រងឯកសាររបស់ DC-Cam, E1/39.1/2, ថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ២០១២។

[៤៤] សំណើសុំឱ្យមានការដាក់បង្ហាញឯកសារពីសម័យនោះ ជាសំណៅដើម នៅក្នុងសវនាការ, E168, ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ១៧។

[៤៥] ចម្លើយតបរបស់សហព្រះរាជអាជ្ញា ទៅនឹង "សំណើសុំឱ្យមានការដាក់បង្ហាញឯកសារពីសម័យនោះ ជាសំណៅដើម នៅក្នុងសវនាការ" របស់ ខៀវ សំផន, E168/1, ថ្ងៃទី ២០ ខែ កុម្ភៈ ឆ្នាំ ២០១២, កថាខណ្ឌ ៨-១៨។

មានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព)[៤៦]៖

៣. វិធាន ៦៧(៣) នៃវិធានផ្ទៃក្នុងតម្រូវឱ្យសហចៅក្រមស៊ើបអង្កេតធ្វើការត្រួតពិនិត្យ និងវាយតម្លៃឯកសារទាំងឡាយ ដើម្បីកំណត់ថាតើជាទូទៅមានភស្តុតាងគ្រប់គ្រាន់ក្នុងការគាំទ្រដល់បទចោទនានាប្រឆាំងនឹងជនជាប់ចោទដែរ ឬយ៉ាងណា។ ដំណើរការនេះតម្រូវជាចាំបាច់នៅក្នុងដំណាក់កាលស៊ើបអង្កេតឱ្យមានការកំណត់នូវភាពពាក់ព័ន្ធ និងផ្តល់តម្លៃជាភស្តុតាងមួយចំនួន ដែលភស្តុតាងទាំងនោះត្រូវបានយោងនៅក្នុងដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយអាចត្រូវបានប្តឹងឧទ្ធរណ៍ទៅអង្គបុរេជំនុំជម្រះ។ អាស្រ័យហេតុនេះ អង្គជំនុំជម្រះសាលាដំបូងធ្វើការសន្មតទៅលើឯកសារនានា ក្នុងដីកាដំណោះស្រាយថាមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាពរបស់វាផង) ហើយអង្គជំនុំជម្រះបានផ្តល់ចំណាត់ថ្នាក់E3 ដល់ឯកសារទាំងនោះ។ ពុំមានការសន្មតជាមុនបែបនេះឡើយ ចំពោះឯកសារទាំងឡាយដែលមាននៅក្នុងសំណុំរឿង ប៉ុន្តែពុំឃើញមានយោងនៅក្នុងដីកាដំណោះស្រាយនោះ។

២១. ពាក់ព័ន្ធនឹងសេចក្តីសម្រេចនាពេលបច្ចុប្បន្ន អង្គជំនុំជម្រះក៏បានសម្រេចដូចខាងក្រោម[៤៧]៖

៤. ឯកសារដើមគឺជាវិធីសាស្ត្រប្រសើរជាងគេនៃការយកមកបង្ហាញជាភស្តុតាង ហើយនឹងត្រូវបានផ្តល់ទម្ងន់ច្រើនជាងឯកសារថតចម្លង។ ការដែលថាពាក្យពេចន៍នៅក្នុងឯកសារមួយពុំអាចអានបាននោះគឺមិនអាចរារាំងការដាក់ឯកសារនោះ ចំពោះមុខអង្គជំនុំជម្រះបានទេ។ បញ្ហាបែបនេះគឺជាប់ពាក់ព័ន្ធនឹងទម្ងន់នៃភស្តុតាង ហើយនឹងមិនត្រូវបានពិចារណាឡើយ នៅពេលវាយតម្លៃអំពីលក្ខខណ្ឌតម្រូវនៃវិធាន៨៧(៣) នៃវិធានផ្ទៃក្នុង។

៥. សម្ភារៈមួយចំនួនដូចជារបាយការណ៍ដែលមានការវិភាគ សៀវភៅ ភាពយន្តឯកសារ និងអត្ថបទដកស្រង់ចេញពីប្រព័ន្ធផ្សព្វផ្សាយ អាចមានការពាក់ព័ន្ធ ហើយនឹងត្រូវរាប់ចូលជាប្រភេទនៃឯកសារមួយផងដែរ។ ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះនឹងពិចារណាសម្រេចអំពីតម្លៃជាភស្តុតាងនៃឯកសារទាំងនេះ នាពេលសមស្របខាងមុខ។

៦. តុលាការព្រហ្មទណ្ឌអន្តរជាតិសម្រាប់អតីតយូហ្គោស្លាវី អាយ.ស៊ី.ធី.វ៉ាយ និងតុលាការព្រហ្មទណ្ឌអន្តរជាតិនានា បានអនុម័តនូវការអនុវត្តដែលថាអនុញ្ញាតឱ្យចៅក្រមដក

[៤៦] ប្រតិចារិក. ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៨៥-៨៨; *សូមមើលផងដែរ* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158, E162, ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ("សង្ខេបសេចក្តីសម្រេចផ្ទាល់មាត់"), កថាខណ្ឌ ៣។

[៤៧] ប្រតិចារិក. ថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៨៥-៨៨; *សូមមើលផងដែរ* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូងទៅនឹងផ្នែកខ្លះនៃឯកសារ E114, E114/1, E131/1/9, E131/6, E136 និង E158, E162, ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ២០១២ ("សង្ខេបសេចក្តីសម្រេចផ្ទាល់មាត់")។

ចេញនូវភស្តុតាង ប្រសិនបើតម្លៃនៃភស្តុតាងនោះមានលក្ខណៈលម្អៀងជាខ្លាំងតាមតម្រូវការនៃការធានាឲ្យមានការជម្រះក្តីប្រកបដោយយុត្តិធម៌។ គោលការណ៍នេះមិនមានចែងនៅក្នុងក្របខ័ណ្ឌច្បាប់ អ.វ.ត.ក ទេ ហើយទោះក្នុងករណីណាក៏ដោយ វាមិនចាំបាច់នោះទេពីព្រោះថាចៅក្រមវិជ្ជាជីវៈ មានសមត្ថភាពក្នុងការដកចេញនូវភស្តុតាងទាំងឡាយណាដែលមានលក្ខណៈបុរេវិនិច្ឆ័យមិនត្រឹមត្រូវ។

៧. ពុំមានលក្ខខណ្ឌតម្រូវផ្នែកនីតិវិធី នៅចំពោះមុខអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ក្នុងការកោះហៅសាក្សីដែលមានចំណេះដឹងផ្ទាល់ខ្លួន យកមកផ្តល់យថាភាពដល់ឯកសារនានានៅក្នុងសំណុំរឿងនោះទេ។ ទោះយ៉ាងនេះក្តី សក្ខីកម្មទាក់ទិននឹងដំណើររក្សាទុកភស្តុតាង និងប្រភពឯកសារ និងជួយដល់អង្គជំនុំជម្រះក្នុងការវាយតម្លៃអំពីទម្ងន់ដែលត្រូវបញ្ជាក់លើឯកសារជាក់លាក់នានា។

៨. កន្លងមក អង្គជំនុំជម្រះសាលាដំបូងបានបញ្ជាក់ថាភាគីនានាដែលស្នើសុំបង្ហាញឯកសារនៅពេលសវនាការ ត្រូវធានាឲ្យទាន់ពេលនូវឯកសារបកប្រែជាភាសាផ្លូវការទាំង ៣ ភាសា (មើលឯកសារ E131/1)។ អង្គជំនុំជម្រះសាលាដំបូងនឹងធ្វើការលើកលែងខ្លះក្នុងករណីដែលភាគីមិនអាចផ្តល់ឯកសារទាំង ៣ ភាសាបាន ដោយសារអង្គភាពបកប្រែភាសាមានទំហំការងារច្រើនពេកមិនអាចបកប្រែឯកសារបានទាន់ពេលវេលា និងផ្នែកពាក់ព័ន្ធនៃឯកសារដែលភាគីមានបំណងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ត្រូវបានយកទៅប្រើជាមូលដ្ឋានក្នុងការសួរដេញដោលសាក្សីឬជនជាប់ចោទ ប្រសិនបើឯកសារនោះមានយ៉ាងហោចណាស់មួយភាសា ហើយជាភាសាដែលជនជាប់ចោទឬសាក្សីអាចយល់បាន។ លើសពីនេះ ផ្នែកពាក់ព័ន្ធខ្លីៗនៃឯកសារដែលអាចងាយស្រួលក្នុងការបកប្រែក្នុងពេលសវនាការ អង្គជំនុំជម្រះអាចអនុញ្ញាតឲ្យយកផ្នែកពាក់ព័ន្ធខ្លីៗនៃឯកសារនោះ មកដាក់ចំពោះមុខជនជាប់ចោទ ឬសាក្សីបាន។

៩. ដោយហេតុថាភាគីបន្តលើកឡើងអំពីបញ្ហានេះ អង្គជំនុំជម្រះសូមបញ្ជាក់ជាថ្មីថាភស្តុតាងដែលទទួលបានតាមរយៈការធ្វើទារុណកម្ម ត្រូវបានយកមកប្រើដោយមានកម្រិត។ អង្គជំនុំជម្រះសូមរំឭកឡើងវិញនូវអនុស្សរណៈ E74 របស់ខ្លួនក្នុងសំណុំរឿង ០០២ និងសេចក្តីសម្រេចផ្ទាល់មាត់ក្នុងសំណុំរឿង ០០១ នៅថ្ងៃទី ២០ និងថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩។

២២. បន្ទាប់ពីមានសេចក្តីសម្រេចនេះ ការជំទាស់របស់មេធាវីការពារក្តីដែលត្រូវបានរៀបរាប់ក្នុងកថាខណ្ឌ ៩(i) និងកថាខណ្ឌ ១៥(i)[៤៨] កថាខណ្ឌ ១៥(v) និងកថាខណ្ឌ ១១ (ពាក់ព័ន្ធនឹងដំណើរ

---

[៤៨] សង្ខេបសេចក្តីសម្រេចផ្ទាល់មាត់, កថាខណ្ឌ ៦។

វក្បាឯកសារទូរលេខ)[៤៩] ១៥ (vii)[៥០] ១៥ (xi)[៥១] និងកថាខណ្ឌ ១១ (ពាក់ព័ន្ធនឹងសៀវភៅ និង អត្ថបទ)[៥២] គឺជាការជំទាស់ដែលគ្មានមូលដ្ឋានសមស្រប។ ការជំទាស់នានាដែលត្រូវបានលើក ក្នុងកថាខណ្ឌ ៩(iv) និង ១៥(ii)[៥៣], កថាខណ្ឌ ១២[៥៤], និង ៩(ii) ក៏ជាការជំទាស់ ដែលគ្មាន

---

[៤៩] សង្ខេបសេចក្តីសម្រេចផ្ទាល់មាត់, កថាខណ្ឌ ៧។ ដោយហេតុថា ក្របខណ្ឌច្បាប់របស់ អ.វ.ត.ក មិនមានលក្ខខណ្ឌតម្រូវឱ្យសាក្សីបង្ហាញភស្តុតាងទេនោះ អវត្តមានព័ត៌មានដែលពាក់ព័ន្ធទៅនឹងប្រភពដើម និងខ្សែសង្វាក់ របស់ទូរលេខ គឺជាបញ្ហាមួយ ដែលត្រូវព្រួយបារម្ភជាងភាពអាចទទួលយកបាន។ នៅគ្រប់ករណីទាំងអស់ អ្នកទទួលបន្ទុកផ្នែកទូរលេខជាច្រើនរូប ត្រូវបានរៀបចំដាក់កាលវិភាគឱ្យផ្តល់សក្ខីកម្មនៅក្នុងរឿងក្តី ០០២/០១ (ប្រតិចារិក., ថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, ទំព័រ ១០)។

[៥០] សង្ខេបសេចក្តីសម្រេចផ្ទាល់មាត់, កថាខណ្ឌ ៨។ ក្រៅពីបន្ទុកទៅលើភាគី ដែលជាអ្នកទាមទារឱ្យបង្ហាញពីឯកសារ ដើម្បីធានាឱ្យឯកសារនោះអាចប្រើប្រាស់ជាបីភាសាផ្លូវការ ដោយទាន់ពេលវេលានោះអង្គជំនុំជម្រះសាលាដំបូង បានផ្តល់សេរីភាពពាក់ព័ន្ធទៅនឹងឯកសារនៅក្នុងជើងទំព័ររបស់ដីកាដំណោះស្រាយ និងឯកសារឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា ដែលយោងកថាខណ្ឌ ៩(iv) និង កថាខណ្ឌ ១៥(vii) ដែលមិនអាចរកបានជាបីភាសាផ្លូវការនៅ អ.វ.ត.ក ដោយសារតែទំហំកិច្ចការរបស់អង្គភាពបកប្រែឯកសារ និងបកប្រែផ្ទាល់មាត់ ដែលរារាំងមិនឱ្យការបកប្រែឯកសារនោះ ប្រព្រឹត្តទៅឱ្យបានទាន់ពេលវេលា (*សូមមើល* ប្រតិចារិក. ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៨៨)។

[៥១] សង្ខេបសេចក្តីសម្រេចផ្ទាល់មាត់, កថាខណ្ឌ ៩។ ពីពេលមុន អង្គជំនុំជម្រះសាលាដំបូង ក៏បានបកស្រាយផងដែរថា ភស្តុតាងដែលប្រមូលបានមកតាមរយៈការធ្វើទារុណកម្ម មានការប្រើប្រាស់មានកម្រិត (*សូមមើល ឧទាហរណ៍.* ប្រតិចារិក. ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ២០១២, ទំព័រ ៨៨; ប្រតិចារិក., ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១, ទំព័រ ៩៦-៩៧; ប្រតិចារិក., ថ្ងៃទី ២០ ខែ ឧសភា ឆ្នាំ ២០០៩, ទំព័រ ៦ និងប្រតិចារិក., ចុះថ្ងៃទី ២៨ ខែ ឧសភា ឆ្នាំ ២០០៩, ទំព័រ ៧-៩)។

[៥២] សង្ខេបសេចក្តីសម្រេចផ្ទាល់មាត់, កថាខណ្ឌ ៥។

[៥៣] *សូមមើលជាឧទា.* ខ្សែអាត់សំឡេងសេចក្តីសម្រេច កថាខណ្ឌ ៦, កថាខណ្ឌ ១២ (បកស្រាយថា បទសម្ភាសន៍របស់សាក្សី ក.ស.ច.ស មិនមែនជាប្រតិចារិកដែលគ្មានល្អៀង ហើយវាមិនមែនជាការចាំបាច់សម្រាប់សហ ចៅក្រមស៊ើបអង្កេត ក្នុងការអាត់យកសំឡេង ឬថតយករូបភាពវីដេអូ បទសម្ភាសន៍ជាមួយសាក្សី ឬដើមបណ្តឹង រដ្ឋប្បវេណីនោះដែរ។ អង្គជំនុំជម្រះ នឹងមានចំណាប់អារម្មណ៍ទៅលើការចោទប្រកាន់នានា ស្តីពីភាពមិនស៊ីសង្វាក់ រវាងខ្សែអាត់សំឡេង និងកំណត់ហេតុជាលាយលក្ខណ៍អក្សរនៃបទសម្ភាសន៍ ចំពោះតែករណីការចោទ ប្រកាន់ទាំងនេះ ត្រូវបានកំណត់ដោយភាគីដែលធ្វើការចោទប្រកាន់ជាមួយនឹងភាពច្បាស់លាស់គ្រប់គ្រាន់ និងចំពោះតែករណីដែលការចោទប្រកាន់ទាំងនោះ ជាប់ពាក់ព័ន្ធទៅនឹងភាពមិនស្របគ្នាដោយអន្លើសំខាន់ៗ ដែលទាក់ទងយ៉ាងច្បាស់ទៅនឹងសវនាការ); *សូមមើលផងដែរ* អនុស្សរណៈអង្គជំនុំជម្រះសាលាដំបូង ដែលមានចំណងជើង សំណើសុំឱ្យមានការបកប្រែសំណើរបស់ នួន ជា E142 និងលិខិតរបស់ អៀង សារី ផ្ញើជូនទៅមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង កាលពីថ្ងៃទី ១១ ខែ ធ្នូ ឆ្នាំ ២០១១ (E142/1), E142/2, ថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ២០១១។ ការបដិសេធទាំងនេះ សហមេធាវីការពារក្តីរបស់ អៀង សារី មិនបានបញ្ជាក់ឱ្យបានលម្អិត ពីភាពមិន ត្រឹមត្រូវ ឬភាពមិនស្របគ្នាដែលបានអះអាងថាបានកើតមាននៅក្នុងកំណត់ហេតុលាយលក្ខណ៍អក្សរនៃការស្តាប់ចម្លើយសាក្សី ហើយមេធាវីការពារក្តី មិនបានផ្តល់មូលហេតុបញ្ជាក់ ហេតុអ្វីបានជា

00798294



មូលដ្ឋានសមស្របដែរ ហើយអង្គជំនុំជម្រះបានបកស្រាយដោយលម្អិតនៅក្នុងសេចក្តីសម្រេច ពាក់ព័ន្ធមួយចំនួន ឬសេចក្តីសម្រេចមុនៗរបស់ ខ្លួនរួចហើយដែរ។ ការជំទាស់ទៅលើ កថាខណ្ឌ ១៥(iii) និង ១៥(iv) នឹងត្រូវសម្រេចដោយសេចក្តី សម្រេចជាលាយលក្ខណ៍អក្សរ នៅពេលអង្គជំនុំជម្រះសម្រេចទៅលើសំណើសុំពាក់ព័ន្ធនឹងចម្លើយសាក្សី[៥៥] និងឯកសារថ្មី[៥៦]។

២៣. ពាក់ព័ន្ធនឹងការជំទាស់ដែលនៅសេសសល់របស់មេធាវីការពារក្តី អង្គជំនុំជម្រះសាលាដំបូងកត់សម្គាល់ឃើញថា ភាគច្រើនលើសលប់ គឺជាការជំទាស់ទូទៅទៅនឹងឯកសារតាមប្រភេទនីមួយៗ ហើយពុំចង្អុលបង្ហាញអំពីចំណុចជាក់លាក់នៃឯកសារណាមួយ ដែលត្រូវបានចោទប្រកាន់ថាបានធ្វើឱ្យឯកសារទាំងនោះមានភាពមិនអាចជឿជាក់បាន ឬមិនអាចឱ្យទទួលយកបាននៅចំពោះមុខអង្គជំនុំជម្រះឡើយ។ ទោះជាយ៉ាងណា អង្គជំនុំជម្រះបានខិតខំពិនិត្យ

---

ការស្តាប់ចម្លើយរបស់ សាក្សីមួយរូបៗ ត្រូវតែបកប្រែជាបីភាសាផ្លូវការរបស់ អ.វ.ត.ក នោះ។ ជាទូទៅ ការចោទប្រកាន់ពាក់ព័ន្ធ នឹងភាពមិនស្របគ្នា រវាងកំណត់ហេតុស្តាប់ចម្លើយស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរ និងជាសំឡេងទាក់ទងទៅនឹងតម្លៃជាភស្តុតាង ដើម្បីទទួលយកកំណត់ហេតុជាលាយលក្ខណ៍អក្សរទាំងនេះ ហើយមិនជាប់ពាក់ ព័ន្ធ ថាតើកំណត់ហេតុស្តាប់ចម្លើយសាក្សីជាលាយលក្ខណ៍អក្សរទាំងនេះ អាចនឹងដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែរឬយ៉ាងណានោះទេ។

[៥៤] *សូមមើល* ចម្លើយតបរបស់អង្គជំនុំជម្រះសាលាដំបូង ទៅនឹងសំណោះ E67, E57, E56, E23, E59, E20, E33, E71 និង E73 បន្ទាប់ពីអង្គប្រជុំស្តីពីការគ្រប់គ្រងសវនាការ ធ្វើឡើងកាលពីថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១១ (បញ្ជាក់ថាប្រសិនជាត្រូវកោះហៅនៅក្នុងសំណុំរឿង ០០២ កាំង ហ្គេកអ៊ាវ *ហៅ ឌុច* នឹងផ្តល់សក្ខីកម្មក្នុងឋានៈជាសាក្សីមួយរូប ហេតុនេះ គាត់នឹងតម្រូវឱ្យស្បថ) និងក្រុមសាក្សី ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកជំនាញបន្ទាប់ ដែលត្រូវផ្តល់សក្ខីកម្មនៅក្នុងសំណុំរឿង ០០២/០១, E172, ថ្ងៃទី ១៧ ខែ កុម្ភៈ ឆ្នាំ ២០១២ (បញ្ជាក់ថា កាំង ហ្គេកអ៊ាវ *ហៅ ឌុច* នឹងផ្តល់សក្ខីកម្មក្នុងអំឡុងពេលសវនាការនាពេលបច្ចុប្បន្ន ក្នុងសំណុំរឿង ០០២/០១)។

[៥៥] ទោះជាយ៉ាងណាក្តី អង្គជំនុំជម្រះធ្លាប់បានសម្រេចដោយផ្ទាល់មាត់រួចហើយថា កំណត់ហេតុនៃការស្តាប់ចម្លើយសាក្សី កាំង ហ្គេកអ៊ាវ ហៅ ឌុច ដោយសហចៅក្រមស៊ើបអង្កេតនៅក្នុងអំឡុងពេលស៊ើបអង្កេតសំណុំរឿង ០០២ ឬ ០០១ ហើយដែលត្រូវបានដាក់ចូលក្នុងសំណុំរឿង ០០២ នោះគឺត្រូវបានចាត់ទុកថាបានដាក់ចំពោះមុខអង្គជំនុំជម្រះ។ សូមមើលផងដែរ ប្រតិចារឹក ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ២០១២ ទំព័រ ៦៥។ ឯកសារជាច្រើននៃកំណត់ហេតុស្តាប់ចម្លើយក៏មាននៅក្នុងបញ្ជីឈ្មោះឯសាររបស់សហព្រះរាជអាជ្ញាដែរ គឺឧបសម្ព័ន្ធ ១២។

[៥៦] អង្គជំនុំជម្រះបានពិនិត្យទៅលើឯកសារថ្មីដែលមាននៅក្នុងឧបសម្ព័ន្ធ ១ ដល់ ឧបសម្ព័ន្ធ ៥ និងដូចដែលបញ្ជាក់នៅក្នុងសេចក្តីសម្រេចទៅលើឯកសារថ្មី ព្រោះឯកសារទាំងនោះបានបំពេញលក្ខខណ្ឌតម្រូវដើម្បីអាចដាក់ចូលទៅក្នុងសំណុំរឿង នឹងដាក់នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូងបាន លើកលែងតែឯកសារចំនួនបួនប៉ុណ្ណោះ៖ ឯកសារមួយក្នុងចំណោមឯកសារទាំងបួនគឺមិនពាក់ព័ន្ធនឹងសំណុំរឿង ហើយឯកសារបីទៀតគឺមិនមានអត្ថិភាព អាចឱ្យអង្គជំនុំជម្រះពិនិត្យបាន។

មើលឡើងវិញទៅលើរាល់ការជំទាស់ពាក់ព័ន្ធទាំងអស់មិនថាជាការជំទាស់ទូទៅ ឬការជំទាស់ជាក់លាក់ឡើយ។ ថ្វីបើដូច្នេះ អង្គជំនុំជម្រះសូមរំឭកឡើងវិញនូវសេចក្ដីជូនដំណឹងរបស់ខ្លួនទៅភាគីថា ភាគីត្រូវបង្ហាញសេចក្ដីជំទាស់ឱ្យបានច្បាស់លាស់ ហើយនៅពេលពុំមានការបញ្ជាក់ឱ្យបានច្បាស់លាស់គ្រប់គ្រាន់ មានតែការជំទាស់ដែលចោទប្រកាន់ថាឯកសារណាមួយខ្វះនូវភាពអាចជឿជាក់បាន ឬភាពជាប់ពាក់ព័ន្ធ យ៉ាងជាក់ច្បាស់ប៉ុណ្ណោះដែលនឹងត្រូវអង្គជំនុំជម្រះពិនិត្យពិចារណា[៥៧]។ ហេតុដូច្នេះ អង្គជំនុំជម្រះសូមបដិសេធការជំទាស់ដែលមានក្នុងកថាខណ្ឌ ៩(iii) ដោយហេតុថាការជំទាស់នេះខកខានពុំបានពន្យល់មូលហេតុដែលឯកសារចំនួន ៨២ នេះ ត្រូវបានចោទប្រកាន់ថាមិនមានភាពអាចជឿជាក់បាន ឬពុំសមស្របដើម្បីបញ្ជាក់អង្គហេតុដែលឯកសារទាំងនោះមានចេតនាបញ្ជាក់។ តាមសំអាងហេតុរបស់ខ្លួននៅក្នុងកថាខណ្ឌ ៣៤ នៃសេចក្ដីសម្រេចនេះ ការជំទាស់ទាំងប៉ុន្មានដែលត្រូវបានលើកក្នុងកថាខណ្ឌ ១៥ (viii) កថាខណ្ឌ ១៥ (ix) និងកថាខណ្ឌ ១៥ (x) ត្រូវបានបដិសេធស្រដៀងគ្នា ដោយហេតុថា ការជំទាស់ទាំងនេះខ្វះភាពជាក់លាក់។

## ៤.២ ការជំទាស់ទាក់ទិននឹងប្រភពនៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

២៤. តាមសំអាងហេតុខាងក្រោម អង្គជំនុំជម្រះបានបដិសេធការជំទាស់ទាំងអស់របស់មេធាវីការពារក្ដីទាក់ទិននឹងប្រភពនៃឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា។

២៥. នាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា លោក វ៉ាន់ថាន់ ដារ៉ា បានផ្ដល់សក្ខីកម្មថា មជ្ឈមណ្ឌលឯកសារកម្ពុជា គឺជាអង្គការឯករាជ្យមិនរកប្រាក់ចំណេញដែលមានបេសកកម្មប្រមូល និងចងក្រងឯកសារសម័យខ្មែរក្រហម[58]។ មជ្ឈមណ្ឌលទទួលឯកសារនានាពីប្រភពផ្សេងៗ រួមទាំងស្ថាប័នរដ្ឋ បណ្ណសារជាតិ រាជរដ្ឋាភិបាលកម្ពុជា អង្គការឯកជន និងការបរិច្ចាគ

---

[៥៧] *សូមមើល* ដីកាកំណត់កាលបរិច្ឆេទបើកសវនាការលើឯកសារដំបូង កថាខណ្ឌ ២។

[៥៨] ប្រតិចារិក., ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ តារ៉ា), ទំព័រ ៥, ១១, ៦៤, ៦៧; ប្រតិចារិក., ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ តារ៉ា), ទំព័រ ១៧ (សាក្សីបានទទួលការបណ្ដុះបណ្ដាល នៅក្នុងការប្រមូល ការគ្រប់គ្រង និងចងក្រងឯកសារនៅ New South Wales, Australia ព្រមទាំងបានទទួល ការបណ្ដុះបណ្ដាល អំពីរបៀបធ្វើការស៊ើបអង្កេតឧក្រិដ្ឋកម្ម នៅក្នុងប្រទេសអៀកឡង់ ក្នុងឆ្នាំ ២០០០។ គាត់បានបម្រើការងារនៅមជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam ចាប់តាំងពីឆ្នាំ ១៩៩៥)។

ផ្ទាល់ខ្លួន[59]។ នៅពេលមជ្ឈមណ្ឌលឯកសារកម្ពុជាទទួលបានឯកសារ ឬសម្ភារៈផ្សេងៗ ខ្លួនធ្វើការស្រាវជ្រាវអំពីប្រភពឯកសារទាំងនោះ រួចថតចម្លង និងរក្សាទុកឯកសារដើមនៅក្នុងទីកន្លែងដែលមានសុវត្ថិភាព។ បន្ទាប់មកទៀត ឯកសារនេះត្រូវបានធ្វើកាតាឡុក និងបញ្ចូលទៅក្នុងមូលដ្ឋានទិន្នន័យ[៦០]។ ឯកសារទាំងអស់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលត្រូវបានធ្វើកាតាឡុកដូចគ្នា មិនថាអាចជាឯកសារដាក់បន្ទុក ឬពុំមែនដាក់បន្ទុកនោះឡើយ[៦១]។ ឯកសារទាំងអស់ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានចងក្រង និងរក្សាទុកគឺសាធារណៈជនអាចពិនិត្យមើលបាន ដោយពុំមានកំហិតលើការប្រើប្រាស់ឯកសារទាំងនោះឡើយ[៦២]។

២៦. លោក ឆាំង យុ ប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាបានអះអាងថាឯកសារដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានទទួលគឺឆ្លងកាត់នីតិវិធីត្រួតពិនិត្យហ្មត់ចត់ដើម្បីធានាអំពីភាពត្រឹមត្រូវ[៦៣]។ ដើម្បីវាយតម្លៃថាតើឯកសារមួយ ជាឯកសារដើម បុគ្គលិកធ្វើការវាយតម្លៃអំពីកាលបរិច្ឆេទនៃឯកសារ លក្ខណៈទូទៅរបស់ឯកសារ និងភាសាដែលត្រូវបានប្រើប្រាស់[៦៤]។ ដើម្បីបញ្ជាក់យថាភាពនៃឯកសារ មជ្ឈមណ្ឌលឯកសារកម្ពុជាក៏ពិនិត្យទៅលើពណ៌របស់ឯកសារដើម្បីវាយតម្លៃថាតើជាឯកសារចាស់ ឬឯកសារថ្មី ហើយនឹងកំណត់កាលបរិច្ឆេទ និងអ្នកនិពន្ធ

---

[៥៩] ប្រតិចារិក., ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ តារ៉ា), ទំព័រ ១២។

[៦០] ប្រតិចារិក., ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ តារ៉ា), ទំព័រ ៦, ១២-១៣។

[៦១] ប្រតិចារិក., ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ តារ៉ា), ទំព័រ ៨៤-៨៥, ទំព័រ ១១៣ (បដិសេធការលើកឡើងរបស់មេធាវីការពារក្តី នួន ជា ដែលថា មជ្ឈមណ្ឌលឯកសារកម្ពុជា DC-Cam មិនបានធ្វើការស្រាវជ្រាវពីប្រវត្តិសាស្ត្រដោយអព្យាក្រឹត្យ ប៉ុន្តែបានព្យាយាមផ្តល់នូវមូលដ្ឋានសម្រាប់សវនាការ តាមរយៈការប្រមូលសេចក្តីថ្លែងការណ៍ដាក់បន្ទុក); *សូមមើលផងដែរ* ប្រតិចារិក., ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាង យុ), ទំព័រ ៧៥។

[៦២] ប្រតិចារិក., ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ តារ៉ា), ទំព័រ ៣០។

[៦៣] ប្រតិចារិក., ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាង យុ), ទំព័រ ៣៣ (ស្ថិតិនោះត្រូវបានអាន សង្ខេប និងបកប្រែ ប្រសិនបើចាំបាច់ ព្រមទាំងផ្ទៀងផ្ទាត់ជាមួយនឹងច្បាប់ចម្លងផ្សេងទៀត ដើម្បីធានាភាពត្រឹមត្រូវ)។ សាក្សីទទួល សញ្ញាប័ត្រអនុបណ្ឌិតផ្នែកវិទ្យាសាស្ត្រនយោបាយ និងបានទទួលការបណ្តុះបណ្តាលនៅមជ្ឈមណ្ឌលឯកសារ នៅឯសាកលវិទ្យាល័យ Yale (ប្រតិចារិក., ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២, ទំព័រ ៥) ។

[៦៤] ប្រតិចារិក., ចុះថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ តារ៉ា), ទំព័រ ១១-១២, ១៧-១៨, ៦៨; ប្រតិចារិក., ថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ តារ៉ា), ទំព័រ ៥១-៥២។

ឯកសារ[65]។ ថ្វីបើមជ្ឈមណ្ឌលឯកសារកម្ពុជាពុំធ្វើកោសល្យវិច័យទៅលើឯកសារក៏ដោយ ក៏មជ្ឈមណ្ឌលពឹងផ្អែកលើបុគ្គលិកប្រកបដោយបទពិសោធន៍ និងបានសហការជាមួយស្ថាប័នជាតិ ដូចជាបណ្ណសារជាតិកម្ពុជាជាដើម[66]។

២៧. នាពេលមានការស្នើសុំ មជ្ឈមណ្ឌលឯកសារកម្ពុជានឹងព្យាយាមតាមដានរកប្រភពដើមនៃឯកសារ[67]។ ប៉ុន្តែលោក ឆាំង យុ បានផ្តល់សក្ខីកម្មថា ពុំមានភាគីណាមួយនៃសំណុំរឿង ០០២ បានធ្វើសំណើមកមជ្ឈមណ្ឌលឯកសារកម្ពុជាដើម្បីស្នើសុំឯកសារដើមឡើយ[68]។ ជាងនេះទៀត មេធាវីការពារជនជាប់ចោទ នួន ជា បានទទួលស្គាល់ថា ពួកគេពុំចោទថាមជ្ឈមណ្ឌលឯកសារកម្ពុជាជាអ្នកបានក្លែងបន្លំឯកសារឡើយ[69]។ ថ្វីបើមេធាវីការពារក្តីអះអាងថាមជ្ឈមណ្ឌលឯកសារកម្ពុជាពុំទាន់មានភាពល្អិតល្អន់គ្រប់គ្រាន់ក្នុងការបញ្ជាក់អំពីប្រភព និងយថាភាពនៃឯកសារក៏ដោយ ក៏សក្ខីកម្មរបស់លោក វ៉ាន់ថាន់ ដារ៉ា និងលោក ឆាំង យុ ពុំមានលក្ខណៈអាចឱ្យជំទាស់តវ៉ាបានឡើយ។

២៨. ផ្អែកលើសក្ខីកម្មរបស់លោក ឆាំង យុ និងលោក វ៉ាន់ថាន់ ដារ៉ា អង្គជំនុំជម្រះសាលាដំបូងយល់ឃើញថា វិធីសាស្ត្រដែលមជ្ឈមណ្ឌលឯកសារកម្ពុជាបានប្រើប្រាស់ក្នុងការទទួលបានឯកសារ ការធ្វើបណ្ណសារ និងការរក្សាទុកឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យ មានភាពអាចឱ្យជឿ

---

[65] ប្រតិចារិក., ចុះថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាង យុ), ទំព័រ ៣៧ (បញ្ជាក់ថា មាតិកា និងការប្រើប្រាស់ភាសានៃឯកសារ ត្រូវបានត្រួតពិនិត្យ ដើម្បីកំណត់ថា តើ ឯកសារទាំងនោះ បានទទួលសិទ្ធិឱ្យបោះពុម្ពផ្សាយនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យដែរឬយ៉ាងណានោះ ហើយការប្រើប្រាស់ភាសានៅក្នុងមជ្ឈមណ្ឌលឯកសារនៃរបបកម្ពុជាប្រជាធិបតេយ្យគឺប្លែកគ្នា)

[66] ប្រតិចារិក., ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ ដារ៉ា), ទំព័រ ១១-១២, ១៧-១៨, ៦៨ (បកស្រាយថា ភាគច្រើនបុគ្គលិករបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានជាប់ពាក់ព័ន្ធនៅក្នុងការប្រមូល និងចងក្រងឯកសារបម្រើការងារក្រោមការត្រួតពិនិត្យរបស់សាក្សី ផ្ទុយទៅវិញបុគ្គលិកឯទៀត បានទទួលការបណ្តុះបណ្តាល នៅក្នុងប្រទេសកម្ពុជាជាមួយអ្នកជំនាញនានា មកពីសាកលវិទ្យាល័យ Yale និងសាកលវិទ្យាល័យ New South Wales); *សូមមើលផងដែរ* ប្រតិចារិក., ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ២០១២ (វ៉ាន់ថាន់ ពៅ ដារ៉ា), ទំព័រ ៥១-៥២ ។

[67] ប្រតិចារិក., ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាង យុ), ទំព័រ ៣៦។

[68] ប្រតិចារិក., ថ្ងៃទី ០១ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាង យុ), ទំព័រ ១២២-១២៣។

[69] ប្រតិចារិក., ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ៨៨; *សូមមើលផងដែរ* ប្រតិចារិក., ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ ទំព័រ ៦១ (បញ្ជាក់ថា ឆាំង យុ បានជួយជ្រោមជ្រែងដល់សហមេធាវីការពារក្តី ដោយបានផ្តល់ព័ត៌មានដល់ក្រុមមេធាវីលោក នួន ជា)។

ជាក់បាន។ ហេតុដូច្នេះ អង្គជំនុំជម្រះយល់ថា ឯកសារពីសម័យកម្ពុជាប្រជាធិបតេយ្យដែលមានប្រភពចេញពីមជ្ឈមណ្ឌលឯកសារកម្ពុជា ត្រូវបានទទួលការសន្មតបឋមនៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព)។ ទោះបីព័ត៌មានទាក់ទិននឹងប្រភព និងដំណើររក្សាឯកសារ ពុំចាំបាច់ត្រូវបានផ្តល់ពាក់ព័ន្ធនឹងឯកសារនីមួយៗដែលត្រូវបានស្នើសុំឱ្យទទួលយកនៅចំពោះមុខអង្គជំនុំជម្រះក៏ដោយ ក៏អង្គជំនុំជម្រះជឿជាក់ថា ដំណើរការដែលត្រូវបានអនុវត្តដោយមជ្ឈមណ្ឌលឯកសារកម្ពុជា ពុំផ្តល់នូវការយល់ឃើញសមហេតុផលណាមួយដែលថា ឯកសារនានាដែលមានប្រភពចេញមកពីប្រភពនេះ អាចបានស្ថិតនៅក្រោមការកែការក្លែង ការបន្លំ ឬក្លែងក្លាយឡើយ[៧០]។ ឯកសារដើមនៃឯកសារទាំងអស់នេះត្រូវបានមជ្ឈមណ្ឌលឯកសារកម្ពុជារក្សាទុក ហើយមេធាវីការពារក្តីអាចបានស្នើសុំពិនិត្យឯកសារទាំងអស់នេះនៅពេលមានបញ្ហាព្រួយបារម្ភជាក់ស្តែង ពាក់ព័ន្ធនឹងភាពត្រឹមត្រូវនៃឯកសារថតចម្លងដែលមាននៅក្នុងសំណុំរឿង ឬពាក់ព័ន្ធនឹងប្រភព ឬភាពអាចជឿជាក់បាននៃឯកសារជាក់លាក់ណាមួយ[៧១]។ ហេតុដូច្នេះ អង្គជំនុំជម្រះសម្រេចថាពុំមានមូលដ្ឋានណាមួយឡើយ ដើម្បីពិនិត្យពិចារណាទៅលើសំណើរបស់មេធាវីការពារជនជាប់ចោទ នួន ជា ស្នើសុំព័ត៌មានបន្ថែមដែលត្រូវបានរក្សាទុកនៅក្នុងមូលដ្ឋានទិន្នន័យនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ឬសំណើរបស់មេធាវីការពារជនជាប់ចោទ ខៀវ សំផន ស្នើសុំផ្តល់ឯកសារដើមទាំងអស់របស់មជ្ឈមណ្ឌលឯកសារកម្ពុជាសម្រាប់ថិរវេលានៃការជំនុំជម្រះ។

## <u>៤.៣. ការជំទាស់ដែលនៅសេសសល់ទៅនឹងឯកសារ ដែលត្រូវបានយោងនៅក្នុងជើងទំព័រពាក់ព័ន្ធនៃដីកាដំណោះស្រាយ និងឯកសារនានាដែលត្រូវបានរៀបរាប់នៅក្នុងឧបសម្ព័ន្ធ A1-A5 របស់សហព្រះរាជអាជ្ញា</u>

២៩. ពាក់ព័ន្ធនឹងការជំទាស់របស់ជនជាប់ចោទ អៀង សារី និងជនជាប់ចោទ នួន ជា ដែលថាឯក

---

[៧០] ប្រតិចារិក., ថ្ងៃទី ០២ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាង យុ), ទំព័រ ១៩, ២១, ៣៦; ប្រតិចារិក., ថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឆាង យុ), ទំព័រ ១០៧-១០៨ (ការច្រានចោលលទ្ធភាព ដែលឯកសារនានានៅក្នុងបណ្ណសារមជ្ឈមណ្ឌលឯកសារកម្ពុជាគួរតែត្រូវបានខិតខំប្រឹងប្រែងដោយបុគ្គលផ្សេងៗទៀត ដោយកត់សម្គាល់ថា វាគឺជាលទ្ធភាពដែលមិនអាចទៅរួច សម្រាប់ជនណាម្នាក់ ដើម្បីបង្កើតឯកសារមិនត្រឹមត្រូវច្រើនជាងមួយលានឯកសារ ព្រមទាំងមិនរួមបញ្ចូលលទ្ធភាព ដែលអ្នកជំនាញជនជាតិវៀតណាម អាចធ្វើឯកសារក្លែងបន្លំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ ដោយយោងបរិមាណ និងលក្ខណៈសម្គាល់ដោយឡែក រួមទាំងអង្គហេតុ ដែលឯកសារជាច្រើន គឺជាភាសាខ្មែរ) ។

[៧១] *ប្រៀបធៀប.* ការបដិសេធជើងទំព័ររបស់ អៀង សារី ទំព័រ ១។

សារចំនួនប្រហែល ១១៩ ក្នុងឧបសម្ព័ន្ធ A1-A5 មិនមានលក្ខណៈអាចឱ្យទទួលយកបានដោយហេតុថា ឯកសារទាំងនោះត្រូវបានបង្ហាញនៅខាងក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក (កថាខណ្ឌ ១៥ (vi))។ អង្គជំនុំជម្រះកត់សម្គាល់ឃើញថា ខ្លួនធ្លាប់បានផ្តល់ការលើកលែងខ្លះដែលមានកម្រិតដល់ភាគី ដើម្បីបង្ហាញភស្តុតាងដែលពុំស្ថិតក្នុងយុត្តាធិការពេលវេលារបស់ អ.វ.ត.ក នៅពេលភស្តុតាងទាំងនោះមានភាពពាក់ព័ន្ធដើម្បីបញ្ជាក់អំពីព័ត៌មាន ឬបរិបទសាវតារ[៧២]។ អង្គជំនុំជម្រះបដិសេធការជំទាស់នេះដោយហេតុថាមេធាវីការពារក្តីពុំបានផ្តល់ទឡ្ហីករណ៍ណាមួយ ដើម្បីគាំទ្រអំណះអំណាងដែលថា សម្ភារៈនេះ ពុំពាក់ព័ន្ធនឹងសវនាការក្នុងសំណុំរឿង ០០២/០១ និងពុំអាចឱ្យទទួលយកបានដោយអនុលោមតាមវិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង។

៣០. ទោះបីឯកសារទាំងនោះពុំមានជាភាសាផ្លូវការទាំងអស់នៅ អ.វ.ត.ក ក៏ដោយ ក៏អង្គជំនុំជម្រះបានពិនិត្យឡើងវិញទៅលើឯកសារទាំងប៉ុន្មាន ដែលត្រូវបានយោងក្នុងកថាខណ្ឌ១៥(vii) និង ៩ (iv) និងចាត់ទុកថា ឯកសារទាំងនោះមានសេចក្តីបញ្ជាក់ដំបូងនៃភាពពាក់ព័ន្ធ និងអាចឱ្យជឿជាក់បាន (រួមទាំងយថាភាព)[៧៣]។ ថ្វីបើភាគីមានសិទ្ធិលើកចំណុចមិនស្របគ្នាសំខាន់ៗរវាងសំណៅជាភាសានានានៃឯកសារទាំងនេះ នៅពេលខ្លួនបានទទួលឯកសារបកប្រែទាំងនេះក៏ដោយ ក៏ចំណុចមិនស្របគ្នានានារវាងសំណៅនៃឯកសារជាភាសានានា (ឬរវាងកំណត់ហេតុជាខ្សែអាត់សំឡេង និងចម្លើយជាលាយលក្ខណ៍អក្សរ) ជាទូទៅ ត្រូវបានចាត់ទុកថា ជាបញ្ហាពាក់ព័ន្ធនឹងតម្លៃជាភស្តុតាង និងទម្ងន់ដែលត្រូវផ្តល់ទៅភស្តុតាងនេះ ជាជាងបញ្ហាដែលថាតើឯកសារនេះគួរត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុងដែរ ឬយ៉ាងណា[៧៤]។

៣១. ទាក់ទិននឹងការជំទាស់របស់មេធាវីការពារក្តី ទៅនឹងនីតិវិធីនៃការដាក់ឯកសារនៅចំពោះមុខ

---

[៧២] សេចក្តីណែនាំនៅមុនពេលសវនាការបឋមពាក់ព័ន្ធនឹងសាក្សីដែលភាគីស្នើសុំកោះហៅ, E93, ថ្ងៃទី ០៣ ខែ មិថុនា ឆ្នាំ ២០១០ (បញ្ជាក់ពីបញ្ហានៃបរិបទជាប្រវត្តិស្ថិតនៅក្រៅយុត្តាធិការពេលវេលារបស់ អ.វ.ត.ក ដែលអាចនឹងត្រូវលើកឡើងនៅក្នុងសវនាការ នៅពេលដែលមានការពាក់ព័ន្ធដែលអាចបើកបង្ហាញឱ្យឃើញពីបញ្ហានានា ស្ថិតនៅក្នុងយុត្តាធិការរបស់ អ.វ.ត.ក និងវិសាលភាពរបស់សវនាការ ដូចដែលអង្គជំនុំជម្រះបានកំណត់)។

[៧៣] *សូមមើល* ជើងទំព័រ ៤៩ ខាងលើ។

[៧៤] *សូមស្តាប់* ខ្សែអាត់សំឡេងសេចក្តីសម្រេច, កថាខណ្ឌ ១២-១៣។

អង្គជំនុំជម្រះ (កថាខណ្ឌ ១១) អង្គជំនុំជម្រះយល់ឃើញថា ពុំមានមូលដ្ឋានណាមួយសម្រាប់អំណះអំណាងដែលថា ឯកសារនានាអាចត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះទាំងស្រុងពាក់ព័ន្ធនឹងសក្ខីកម្មរបស់សាក្សី អ្នកជំនាញ ឬដើមបណ្តឹងរដ្ឋប្បវេណីណាម្នាក់ឡើយ។ ហើយក្របខ័ណ្ឌគតិយុត្តនៅ អ.វ.ត.ក ក៏ពុំតម្រូវឲ្យពិភាក្សាទៅលើខ្លឹមសារទាំងស្រុងនៃឯកសារ មុនពេលការពិចារណាថាឯកសារទាំងនោះបានត្រូវដាក់ចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន៨៧(៣) នៃវិធានផ្ទៃក្នុងដែរ[៧៥]។ ផ្ទុយពីនេះ វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុងត្រូវបានធ្វើវិសោធនកម្មដើម្បីអនុញ្ញាតឲ្យមាន "ការកំណត់អត្តសញ្ញាណសមស្រប" នៃឯកសារជំនួសឲ្យការអានដ៏យូរនៅក្នុងសវនាការអំពីខ្លឹមសារនៃឯកសារនានាដើម្បីធានាបាននូវប្រសិទ្ធភាពនៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះ[៧៦]។ វិសោធនកម្មនេះពុំបណ្តាលឲ្យខូចប្រយោជន៍របស់ជនជាប់ចោទឡើយ ដោយហេតុថា មេធាវីការពារក្តីមានសិទ្ធិក្នុងការជំទាស់ទៅនឹងផ្នែកនានានៃឯកសារដែលអង្គជំនុំជម្រះ ឬភាគីបានស្នើសុំដាក់នៅចំពោះមុខអង្គជំនុំជម្រះ។

៣២. ចំណុចចុងក្រោយ អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាសម្រេចនៅពេលសមស្របខាងមុខថាតើអ្នកជំនាញឈ្មោះ Steven Heder ដែលភាគីស្នើសុំកោះហៅ នឹងត្រូវអង្គជំនុំជម្រះកោះហៅឲ្យចូលបង្ហាញខ្លួននៅចំពោះមុខអង្គជំនុំជម្រះដែរ ឬទេ សម្រាប់គោលបំណងនៃការបញ្ជាក់យថាភាពនៃឯកសារទាំងឡាយ ដែលជាស្នាដៃរបស់គាត់នៅក្នុងជើងទំព័រនៃដីកាដំណោះស្រាយដែលពាក់ព័ន្ធ[៧៧]។ ក្នុងករណីបែបណាក្តី អង្គជំនុំជម្រះសាលាដំបូងនឹងពិចារណាអំពីការជំទាស់របស់មេធាវីការពារជនជាប់ចោទ អៀង សារី (កថាខណ្ឌ ១០) នៅពេលវាយតម្លៃអំពីទម្ងន់ដែលត្រូវផ្តល់ទៅឯកសារនានាក្នុងចំណោមឯកសារទាំងនេះ។

## <u>៤.៤ ឯកសារនានាដែលពុំមានការសន្មតថាមានភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន</u>

---

[៧៥] *ប្រៀបធៀប.* ញត្តិគ្រប់គ្រងសវនាការរបស់ ខៀវ សំផន, កថាខណ្ឌ ២០។

[៧៦] វិធាន ៨៧(៣) នៃវិធានផ្ទៃក្នុង, ត្រូវបានធ្វើវិសោធនកម្ម នៅថ្ងៃទី ១១ ខែ កញ្ញា ឆ្នាំ ២០០៩ ផ្នែកពាក់ព័ន្ធនៃ វិធាននេះចែងថា "ភស្តុតាងដែលមាននៅក្នុងសំណុំរឿង ត្រូវបានចាត់ទុកថា បានលើកឡើងនៅចំពោះមុខ អង្គជំនុំជម្រះ [...]បើសិនជាខ្លឹមសាររបស់វាត្រូវបានសង្ខេប ត្រូវបានអាន ឬត្រូវបានកំណត់បង្ហាញអត្តសញ្ញាណយ៉ាងសមស្របក្នុងសវនាការ"។

[៧៧] អង្គជំនុំជម្រះ នៅមិនទាន់សម្រេចលើអ្នកជំនាញដែលត្រូវបានស្នើសុំរូបនេះ នៅក្នុងបញ្ជីឈ្មោះសាក្សី អ្នកជំនាញ និងដើមបណ្តឹងរដ្ឋប្បវេណីបណ្តោះអាសន្នរបស់ខ្លួន ដែលនឹងត្រូវកោះហៅ នៅក្នុងអំឡុងពេលសវនាការបំបែកពីខាងដើម នៅក្នុងសំណុំរឿង ០០២/០១ (E131/1.1) នៅឡើយទេ។

៣៣. ក្នុងចំណោមឯកសារចំនួនប្រហែល ១១០០ ដែលមាននៅក្នុងឧបសម្ព័ន្ធ A1-A5 ឯកសារចំនួនប្រហែល ២៥០ គឺជាឯកសារដែលពុំបានទទួលពីបណ្ណសារនៃមជ្ឈមណ្ឌលឯកសារកម្ពុជា ឬដែលពុំត្រូវបានលើកក្នុងជើងទំព័រនៃដីកាដំណោះស្រាយពាក់ព័ន្ធ។ ហេតុដូច្នេះថ្វីបើឯកសារទាំងនេះពុំទទួលបាននូវការសន្មតនៃសេចក្តីបញ្ជាក់ដំបូងនៃភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បានក៏ដោយ ក៏អង្គជំនុំជម្រះសាលាដំបូងបានពិចារណាទៅលើឯកសារនីមួយៗនៃឯកសារទាំងនេះ (និងការជំទាស់ពាក់ព័ន្ធទាំងអស់) ដោយផ្អែកទៅលើលក្ខខណ្ឌដូចមានចែងក្នុងវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុង។ នៅពេលពិនិត្យឡើងវិញ ភាគច្រើននៃឯកសារទាំងនេះក៏ត្រូវបានរកឃើញថាមានសេចក្តីបញ្ជាក់ *បឋម* នៃភាពពាក់ព័ន្ធនិងភាពអាចជឿជាក់បាន និងដូច្នេះត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះដោយអនុលោមតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង និងត្រូវបានផ្តល់ចំណាត់ថ្នាក់ E3។

៣៤. អង្គជំនុំជម្រះសាលាដំបូងក៏បានបដិសេធពុំប្រើប្រាស់ការសន្មតអំពីភាពពាក់ព័ន្ធ និងភាពអាចជឿជាក់បាន (រួមទាំងយថាភាព) សម្រាប់ឯកសារទាំងអស់ដែលត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះសាលាដំបូងក្នុងសំណុំរឿង ០០១ ដូចដែលសហព្រះរាជអាជ្ញាបានស្នើ[៧៨]។ ទោះបីជាមានការបញ្ជាក់ថា ឯកសារទាំងនេះបន្ទាប់មកត្រូវបានអង្គជំនុំជម្រះសាលាដំបូង ចាត់ទុកថាមានភាពអាចជឿជាក់បានក៏ដោយ ក៏វាពុំបញ្ជាក់ថា ឯកសារទាំងនេះពាក់ព័ន្ធទៅនឹងសំណុំរឿង ០០២/០១ ដែរ។ ទោះដូច្នេះក្តី ភាពអាចជឿជាក់បានដែលត្រូវបានផ្តល់ទៅឯកសារទាំងនេះក្នុងសំណុំរឿង ០០១ គឺជាកត្តាមួយដែលអង្គជំនុំជម្រះសាលាដំបូងត្រូវពិចារណាក្នុងការសម្រេចថាតើលក្ខខណ្ឌតម្រូវនៃវិធាន ៨៧ នៃវិធានផ្ទៃក្នុងត្រូវបានបំពេញដែរ ឬទេ។

## ៤.៥ សេចក្តីសន្និដ្ឋាន

៣៥. ក្នុងចំណោមឯកសារទាំងអស់ដែលត្រូវបានពិចារណានៅក្នុងសេចក្តីសម្រេចនេះ អង្គជំនុំ-ជម្រះបានបដិសេធឯកសារចំនួន ១៣។ អង្គជមនុំជម្រះបានរកឃើញថា ឯកសារចំនួន ០៩ ពុំពាក់ព័ន្ធនឹងការជំនុំជម្រះលើសំណុំរឿង ០០២/០១ ឬពុំអាចជឿជាក់បាន និងឯកសារមួយគឺមិនអាចអានរួច។ បន្ថែមពីលើនេះទៀត អង្គជំនុំជម្រះនឹងសម្រេចនៅពេលក្រោយទៅលើ

[៧៨] ប្រតិចារិក ចុះថ្ងៃទី ១៩ ខែ មករា ឆ្នាំ ២០១២, ទំព័រ ១៣។

ឯកសារចំនួនបី នៅក្នុងសេចក្ដីសម្រេចលើឯកសារថ្មី ដែលឯកសារទាំងនោះមិនមានអត្ថិភាពអាចឱ្យអង្គជំនុំជម្រះពិនិត្យមើលបាន។

៣៦. ដើម្បីងាយស្រួលយោង អង្គជំនុំជម្រះបានរាយនាមឯកសារទាំងអស់ដែលត្រូវបានដាក់នៅចំពោះមុខអង្គជំនុំជម្រះ ដែលជាលទ្ធផលនៃសេចក្ដីសម្រេចនេះ នៅក្នុងឧបសម្ព័ន្ធ ក (ពាក់ព័ន្ធនឹងឯកសារដែលមាននៅជើងទំព័រនៃដីកាដំណោះស្រាយ) និង ខ (ពាក់ព័ន្ធនឹងបញ្ជីឯកសាររបស់សហព្រះរាជអាជ្ញា ឧបសម្ព័ន្ធ A1 ដល់A5)។

**តាមសំអាងហេតុខាងលើ អង្គជំនុំជម្រះសាលាដំបូង៖**

**ដាក់** ចំពោះមុខអង្គជំនុំជម្រះនូវឯកសារទាំងឡាយដែលត្រូវបានយោងក្នុងដីកាដំណោះស្រាយត្រង់កថាខណ្ឌពាក់ព័ន្ធនឹងសេចក្ដីសម្រេចនេះ ដូចដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ក នៃសេចក្ដីសម្រេចនេះ (ឯកសារ E185.1) លើកលែងតែឯកសារមួយដែលមិនអាចអានរួចប៉ុណ្ណោះ។

**ដាក់** ចំពោះមុខអង្គជំនុំជម្រះនូវឯកសារសម័យកម្ពុជាប្រជាធិបតេយ្យដែលមានប្រភពមកពីមជ្ឈមណ្ឌលឯកសារកម្ពុជាដែលមាននៅក្នុងឧបសម្ព័ន្ធ A1 ដល់ A5 ដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងឧបសម្ព័ន្ធ ខ នៃសេចក្ដីសម្រេចនេះ (ឯកសារ 185.2) លើកលែងតែឯកសារចំនួនដប់ពីរដែលរៀបរាប់ក្នុងកថាខណ្ឌ ៣៥ ខាងលើ។

**បដិសេធ** សារណាបន្ថែមដែលទាក់ទងនឹងសំណើសុំបំភ្លឺអំពីប្រភពនៃឯកសារ ឬដំណើរការរក្សាឯកសាររបស់មជ្ឈមណ្ឌលឯកសារកម្ពុជា (ឯកសារ E1/39.1/1) និងសំណើរបស់ ខៀវ សំផន ដែលស្នើសុំឱ្យមានការដាក់បង្ហាញឯកសារពីសម័យនោះ ដែលមជ្ឈមណ្ឌលឯកសារកម្ពុជាមានជាសំណៅដើមនៅក្នុងសវនាការ និងស្នើសុំឱ្យ អ.វ.ត.ក រក្សាទុកឯកសារទាំងនោះសម្រាប់ថេរវេលានៃការជំនុំជម្រះលើ សំណុំរឿង ០០២ (ឯកសារ E168) ដោយហេតុថា សំណើសុំទាំង២ មិនបានបង្ហាញឱ្យឃើញនូវភាពចាំបាច់ ដែលតម្រូវឱ្យធ្វើដូច្នេះ។

**រំពឹងឡើងវិញ** ថាតម្លៃជាភស្តុតាង និងទម្ងន់ដែលត្រូវផ្តល់ទៅភស្តុតាងដែលត្រូវបានដាក់ចំពោះមុខអង្គជំនុំជម្រះដោយអានុភាពនៃសេចក្តីសម្រេចនេះ នឹងត្រូវអង្គជំនុំជម្រះពិចារណាសម្រេច នៅពេលពិភាក្សាសម្រេចចេញសាលក្រម បន្ទាប់ពីបញ្ចប់សវនាការលើភស្តុតាងក្នុងសំណុំរឿង ០០២/០១ ។

ភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០១២
ប្រធានអង្គជំនុំជម្រះសាលាដំបូង

និល ណុន